# ការសម្ភាសរបស់អ៊ុំស្រី ឡាច ម៉ៅ

**កៈ អ្នកសម្ភាសឈ្មោះ លន់ មុណាក់ អ្នកត្រូវគេសម្ភាសឈ្មោះ ឡាច ម៉ៅ**

កៈ ជាដំបូងនាងខ្ញុំសូមជំរាបសួរអ៊ុំ! ខាងសាលាមួយនៅសហរដ្ឋអាមេរិចគេហៅថាសាកលវិទ្យាល័យប៊ីវាយូ! ហើយគេមានគម្រោងមួយគឺការសម្ភាសប្រជាជនខ្មែរពីប្រវត្តិនឹងខ្សែជីវិតរបស់ពួកគាត់។ អញ្ចឹងថ្ងៃនេះខាងសាលាគេបានអញ្ជើញខ្ញុំមកអោយធ្វើការសម្ភាសអ៊ុំពីខ្សែជិវិតរបស់អ៊ុំកាលពីជំនាន់សម័យប៉ុពត! តើអ៊ុំបានឆ្លងកាត់នៅការលំបានអ្វីខ្លះ? អញ្ចឹងតើខ្ញុំអាចសូមអ៊ុំសម្ភាសហើយសួរអ៊ុំពីមួយនឹងតើបានទេ?

ខៈ ចាសបាន!

កៈ ចាសអរគុណច្រើនអ៊ុំ!

កៈ អញ្ចឹងខ្ញុំអ្នកសម្ភាសខ្ញុំឈ្មោះៈ លន់ មុណាក់។ ហើយថ្ងៃនេះជាថ្ងៃទី២៧,ខែ ០៥,ឆ្នាំ ២០២០។ អញ្ចឹងតើអ៊ុំស្រីមានឈ្មោះអ្វីដែល?

ខៈ អ៊ុំឈ្មោះៈ ឡាច ម៉ៅ។

កៈ អ៊ុំស្រីឡាចម៉ៅ! ចាស។

ខៈ ចាស!ឪពុករបស់ខ្ញុំគាត់ឈ្មោះឡាចហើយខ្ញុំឈ្មោះម៉ៅ។

កៈ ចាសអ៊ុំ! អញ្ចឹងតើឥឡូវនេះអ៊ុំស្រីមានអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំមានអាយុ៥៥ឆ្នាំហើយ។

កៈ ៥៥ឆ្នាំហើយ!?

ខៈ ចាស!

កៈ អញ្ចឹងតើអ៊ុំមានចាំពីថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងដែលទេ?

ខៈ អ៊ុំអត់ចាំទេ! អ៊ុំភ្លេចអស់ហើយ។ ហើយម្ដាយក៏ចោលសៀវភៅចោលអីអស់រលីង។

កៈ ចាសអ៊ុំ!

ខៈ ខ្ញុំដឹងតែថាខ្ញុំកើតឆ្នាំម្សាញ់។

កៈ តែអ៊ុំអត់ដឹងថាអ៊ុំបានកើតនៅឆ្នាំណាអីឆ្នាំណាទេន៍អ៊ុំ?

ខៈ ខ្ញុំដឹងតែថាខ្ញុំកើតនៅជំនាន់លក់ណុល។

កៈ ជំនាន់លន់ណុល ៧០ ជាងឬក៏៦០ជាង?

ខៈ ជំនាន់លន់ណុលហាស់! នៅពេលដែលលន់ពុលចូលមកខ្ញុំដឹងអីអស់ហើយ។

កៈ ចាសអ៊ុំ! អញ្ចឹងអ៊ុំអត់ចាំពីឆ្នាំកំនើតរបស់អ៊ុំទេ?

ខៈ ចាស!

កៈ ចុះ! តើអ៊ុំមានចាំពីកន្លែងដែលអ៊ុំកើតដែលទេ?

ខៈ ខ្ញុំកើរនៅនឹងឯង! នៅនឹងភូមិអូរដំបងនឹង។

កៈ នៅភូមិអូរដំបង! ចា!

ខៈ ចាស! កើតនៅភូមិអូរដំបង, ឃុំអូរដំបង, ស្រុកសង្កែ, ខេត្តបាត់ដំបង, កូនខ្ញុំអីទាំងអស់ក៏កើតនៅនឹងដែល។

កៈ ចាសអ៊ុំ!

ខៈ ចាសកើតនៅនឹងអូរដំបងនឹងឯង!

កៈ ចាសអ៊ុំ! អញ្ចឹងក្រៅពីភាសាខ្មែរតើអ៊ុំមានចេះភាសាអីផ្សេងក្រៅពីភាសាខ្មែរទៀតដែលអត់?

ខៈ ខ្ញុំមិនចេះអីទេ! បើអក្សរខ្ញុំមិនចេះផងនោះ។

កៈ ចាស! អញ្ចឹងអ៊ុំអត់ចេះអានអត់ចេះសរសេរទេន៍អ៊ុំ?

ខៈ ចាស! អត់ទាំងអស់។

កៈ ចាស!

ខ៖ ហើយបើគេសួរចេះតែឆ្លលយទៅ។

ក៖ ចាស!

ខ៖ ចាសហាហា! អក្សរក៏ខ្ញុំមិនចេះអីក៏ខូមមិនចេះដែល។ ពីព្រោះនៅជំនាន់នឹងបែកបាក់អស់ហើយ។

ក៖ ចាសអ៊ុំ! អញ្ចឹងអ៊ុំស្រីឈ្មោះ៖ ឡាចម៉ៅ?

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំមានឈ្មោះហៅក្រៅអីដែលផ្សេងពីនឹងទៀតដែលអត់?

ខ៖ ឈ្មោះគេហៅមានឈ្មោះសាម៉ែតទៅ! ហើយឈ្មោះយាយហែមយាយអីទៅ! ចេះតែតាមដែលគែហៅទៅណាស់។

ក៖ ចាស!

ខ៖ ចេះតែតាមគេហៅទៅ! ដូចជាមីកាបិមីកាបាក់អីចេះតែតាមគែហៅទៅ។

ក៖ ចាសអ៊ុំ! អញ្ចឹងតើមកដល់ពេលឥឡូវនេះគេហៅអ៊ុំអញ្ចឹងដែលនេះ?

ខ៖ ឥគឡូវគេហៅខ្ញុំថាម៉ៅហើយនឹងគេហៅថាហែម។

ក៖ ចាសនឹង! អញ្ចឹងដោយសារតែថ្ងៃខែឆ្នាំកំនើតអ៊ុំអត់ចាំទេ?

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំស្រីមានចាំពីថ្ងៃដែលអ៊ុំស្រីបានរៀបអាពាហ៍ពិពាហ៍ទេ?

ខ៖ ដូចជាខេប៉ុន្មានឆ្នាំប៉ុន្មានទេ?

ក៖ ឆ្នាំដែលអ៊ុំបានរៀបការហាស់?

ខ៖ អូ! ឆ្នាំដែលអ៊ុំរៀបការគឺនៅឆ្នា ៨៦។

ក៖ ចានៅឆ្នាំ ៨៦! ចុះអ៊ុំមានចាំថ្ងៃដែលអត់ទេ?

ខ៖ អូចាស! អ៊ុំភ្លេចអស់ហើយកូន។

កៈ ចាសអ៊ុំ!

ខៈ សាមសិបជាងអស់ហើយដឹង?

កៈ ចាស! អត់អីទេអ៊ុំ។ អញ្ចឹងអ៊ុំបានរៀបការនៅឆ្នាំ ១០៩៨៦១, ១៩៨៦ ណាអ៊ុំ?

ខៈ ចាសចាស!

កៈ តើការរៀបការរបស់អ៊ុំនឹងត្រូវបានរៀបចំឡើងដោយឪពុកម្ដាយឬក៏អ្នកណាជាអ្នករៀបចំអោយអ៊ុំដែល?

ខៈ ឪពុកម្ដាយជាអ្នករៀបចំអោយ។

កៈ អញ្ចឹងតើមានបណ្ដាការឬក៏ការស្ដិដណ្ដឹងអីដែលទេ?

ខៈ អូ!កាលនឹងឪពុកអត់នៅទេ! នៅតែម្ដាយ។

កៈ អូចា!

ខៈ នៅតែម្ដាយដូចគ្នាអត់មានឪពុកទេ! (ខាងប្ដីរបស់អ៊ុំក៏ចឹងដេល)។

កៈ ចាអ៊ុំ! អញ្ចឹង, ខ្ញុំចង់សួរហើយនឹងអ៊ុំប្រុស! តើអ៊ុំទាំងពីបានជួបគ្នាតាមរយៈណាដែល?

ខៈ ជួបគ្នាតាមរយៈច្រូតស្រូវ។

កៈ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំអាចប្រាប់ខ្ញុំអោយបានលំអិតតិចបានទេអំពីការជួបគ្នារបស់អ៊ុំទាំងពីរនឹង! ធ្វើម៉េចបានបានឈានចូលទៅដល់ការរៀបការ?

ខៈ ខ្ញុំទៅច្រូចស្រូវទៅ! ដូចថាគេចាប់ខ្ញុំទៅ ( ប្ដីរបស់គាត់ ) ដល់ពេលគាត់ចាប់ខ្ញុំទៅហើយទៅក៏បានគ្នាទៅ។

កៈ អូហាហាចាស!

ខៈ ហើយគេចាប់ខ្ញុំនៅវាយស្រែ។ កន្លែងកាប់អូសនៅរាំងក្រោលហោក។ កន្លែងកាប់អូសហាស់! ចាស, ហើយទៅកាប់ទៅក៏បានគ្នាទៅ។

កៈ ចាសអ៊ុំ!

ខ៖ ដល់ពេលទៅឡើងស្រែទៅរៀបចំអោយអីទៅ។ ហើយក៏មានកូនចៅមានអីទៅ។ ហើយក៏វេទនារកអីហូបក៏មិនបានដែល?

ក៖ ចាស! អញ្ចឹងតាំងពីពេលដែលអ៊ុំរៀបការមកហើយ! តើអ៊ុំមានកូនចៅប៉ុន្មាននាក់ដែលអ៊ុំ?

ខ៖ អ៊ុំមានកូនចៅតែបួននាក់ទេ!

ក៖ អូ! តើពួកគាត់មានគ្រួសារអស់ហើយអ៊ុំ?

ខ៖ មាន! មានបីនៅមួយ, នៅកូនពៅ! នៅមួយដែលដើរលើៗនឹង។

ក៖ ចាសអ៊ុំ! អញ្ចឹងពៅគេអាយុប៉ុន្មានដែលអ៊ុំ?

ខ៖ អាយុ១១ឆ្នាំហើយ។

ក៖ ចាស១១ឆ្នាហើយ!

ខ៖ ចាស! ហើយជ្រមុជទឹករួចហើយ។

ក៖ ចាស!អញ្ចឹងតើគាត់ជ្រមុជនឹងយូរហើយឬនៅអ៊ុំ?

ខ ជ្រមុជទឹកតំណាលខ្ញុំនឹង។ ជ្រមុជទឹកជាមួយខ្ញុំនឹងឯងជាមួយបងបងរបស់វាអី។ អត់តែមួយទេដែលអត់ទាន់ជ្រមុជទឹក។

ក៖ចាស! អញ្ចឹងសមាជិកទាំងអស់គ្នានៅតែអ៊ុំប្រុសមួយទៀតទេ?

ខ៖ ចាស! ខ្ញុំនឹងខំឃំរុញអោយគាត់ទៅព្រះវិហារហើយអោយចាប់ផ្តើមជ្រមុជទឹក។ អត់អោយនៅទេ។

ក៖ ចាស! នឹងហើយអ៊ុំ។ អញ្ចឹងដោយសារតែអ៊ុំបានគ្នាមុចចឹងពេលដែលចូលស្ដីដណ្ដឹងតើមានបណ្ណាការអីដែលឬអត់?

ខ៖ អត់មានទេ!

ក៖ ហើយក៏សែនយកតែម្តង?

ខ៖ ចាសសែនយកតែម្តង។

ក៖ ចាសអ៊ុំ!

ខ៖ ចាស! ហើយតាំងពីបាននឹងគ្នាមក! ក៏ឡើងពីស្រែពីស្រូវអីមកក៏រៀបចំទុកដាក់អីទៅ។ ហើយមានមហាមានអីទៅ។ ហើយមហាកាលនឹងថ្លៃណាស់!

ក៖ ចាសអ៊ុំ!

ខ៖ ហើយរៀបចំមហូបកាលនឹងពីរចានដែក។ ម្ហូបតិចតតួចនឹង។

ក៖ ចាសអ៊ុំ! អញ្ចឹងមននៃថាអ៊ុំប្រុសមានចិត្តស្រឡាញ់លើអ៊ុំស្រីមុខហី?

ខ៖ នឹងហើយ! ដោយដារតែគាត់ស្រឡាញ់ខ្ញុំមុខនឹងហើយបានជាគាត់ចាប់ខ្ញុំនឹងហូ!

ក៖ ចាស! ឬក៏អ៊ុំស្រឡាញ់គញនាទៅវិញទៅមក? ហើយចឹងកាលនឹងអ៊ុំអត់ទាន់ស្រឡាំញ់ទេ?

ខ៖ ចាសអត់ទេ! កាលនឹងខ្ញុំអត់ទាន់ស្រឡាញ់ផង។ ប៉ុន្តែគេបញ្ឆោតខ្ញុំអោយទៅ( ប្តីរបស់គាត់) ហើយគេបបួលខ្ញុំអោយទៅកាប់អុស។ ហើយក៏មានពីរទេះ! ហើយរទេះរបស់គាត់ក៏ទៅខាងណោះទៅហើយរទេះរបស់ខ្ញុំក៏ទៅខាងនោះទៅ។ មិនដឹងថាគេវាមានចំណងយ៉ាងម៉េចទេ។

ក៖ ចាសអ៊ុំ!

ខ៖ អត់ដឹងអត់ដឹងថាគេមានបំណងចាប់យើង! យើងវាមិនដឹង។

ក៖ ចាសអ៊ុំ!

ខ៖ ហើយដល់ពេលអញ្ចឹងអាទេះមួយនោះក៏គៃទៅបាត់ទៅ! ហើយនៅតែអាទេះយើងនឹង។ ហើយយើងទៅស្រែរកនរណារួចបើស្ងាត់សឹងហូ!

ក៖ ចាសអ៊ុំ!

ខ៖ ហើយបើស្រែក៏ស្រែមិនកើតដែល។

ក៖ ចាស!

ខ៖ វាអញ្ចឹងេងង!

ក៖ អញ្ចឹងពេលដែលអញ្ចឹងហើយទៅ! អញ្ចឹងឪពុករបស់អ៊ុំគាត់ស្លាប់ហី?

ខ៖ ចាស! ឪពុករប់ខ្ញុំគាត់ស្លាប់នៅតែខ្ញុំទេ។ គាត់ទឹមតែស្លាប់បានមួយឆ្នាំ! អូ! ដូចជាបានបីឆ្នាំហើយ។

ក៖ នឹងគាត់ជាម្ដាយរបស់អ៊ុំហ្ស?

ខ៖ ចាស!

ក៖ ចាអ៊ុំស!

ខ៖ គាត់បានស្លាប់ចូលបួនឆ្នាំ, ឆ្នាំនេះហើយ។

ក៖ អញ្ចឹងតើអ៊ុំមានចាំឈ្មោះ! តើអ៊ុំអាចប្រាប់ឈ្មោះម្ដាយឪពុករប់អ៊ុំហើយនឹងជីជីនជីតារបស់មកខ្ញុំបានទេ?

ខ៖ ម្ដាយរបស់ខ្ញុំឈ្មោះរឿត! ហើយឿពុករបស់ខ្ញុំឈ្មោះឡាច។

ក៖ ចាសអ៊ុំ! ចុះឈ្មោះរបស់ជីដូនជីតារបស់អ៊ុំវិញ?

ខ៖ ជីដូនជីតាឈ្មោះយ៉ាន់, ឈ្មោះយាយយ៉ាន់, ហើយតាឈ្មោះតាជា! ហើយបើរ៉ាប់ខាងឪពុកនោះ៖ ឈ្មោះតាសិប, ហើយយាយសិន។

ក៖ ចាសអ៊ុំ!

ខ៖ ហើយខ្ញុំមិនដឹងទេថាខាងគែនោះឈ្មោះអីឈ្មោះអីខ្ញុំបានភ្លេចអស់ហើយ?

ក៖ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំមានចាំពីថ្ងៃខែឆ្នាំកំណើតរបស់ឪពុកម្ដាយរបស់អ៊ុំដែលឬទេ? ហើយជីដូនជីតារបស់អ៊ុំដែលតើអ៊ុំចាំទេ?

ខ៖ អូ! ខ្ញុំអត់ចាំទេ!

ក៖ អត់ចាំទេន៍អ៊ុំ?

ខ៖ ចាសអត់!

ក៖ ចាស! ហើយចុះតើម្ដាឪពុកយរបស់អ៊ុំតើគាត់បានស្លាប់នៅឆ្នាំណាដែល?

ខ៖ គាត់ស្លាប់នៅឆ្នាំ! តាំងពីរ៧៧។ គេយកគាតត់ទៅសម្លាប់។

កះ ចាសអ៊ុំ!

ខះ គេយកគាត់ទៅសម្លាប់ចោល។

កះ ចាសអ៊ុំ! ចុះម្ដាយរបស់អ៊ុំវិញ?

ខះ ម្ដាយរបស់ខ្ញមទែមតែស្លាប់បានបួនឆ្នាំនេះ!

កះ ចាស! អញ្ចឹងគាត់បានស្លាប់នៅឆ្នាំ២០០៦? ចា?

ខះ ចាសចាស!

កះ ២០១៦, គាត់ស្លាប់។

ខះ ចាស! ហើយគាត់ស្លាប់នៅនឹងទីនេះឯង!

កះ ចាសអ៊ុំ! ម្ដាយអ៊ុំដែលស្លាប់នឹងតើគាត់ឈើហីអ៊ុំ?

ខះ គាត់ឈើបានទៃមួយយប់មួយថ្ងៃនឹង។

កះ ហ៊ី! តើគាត់កើតរោគអីដែលអ៊ុំ?

ខះ មុនដំបូងគាត់កើតរោគទឹកនោមផ្អែម! ហើយដល់ពេលកើតទឹកនោមផ្អែមអញ្ចឹងទៅគាត់អត់ហ៊ានហូបអីទេ។ ដល់តែបែលយប់ឡើងនេក, គាត់ញាក់! ហើយមួយនោះគាត់យកនំអន្សមមកអោយពីរ!

កះ ចាអ៊ុំស!

ខះ ហើយគាត់ហូបនំអន្សមអស់ពីរ! គាត់អត់ឈ្លានសោះនោះតែគាត់ហូបអស់ពីរ, ពីរនាក់ថៅរបស់គាត់ទៅ!

កះ ចាសចាសអ៊ុំ!

ខះ ហើយដល់ពេលដែលគាត់ពិសារហើយទៅ, ដល់ពេលយប់ឡើងគាត់រាគ! ហើយដល់ពេលរាគរួចហើយទៅ!

កះ ចាសសអ៊ុំ!

ខ៖ ដល់ពេលយកទៅដល់ពេទ្យក៏គាត់ស្លាប់នៅនឹងពេទ្យនឹងប៉ុនដោយទៅណាស់!

ក៖ ចាសចាអ៊ុំស!

ខ៖ ហើយគាត់បានស្លាប់នៅនឹងពេទ្យនឹងទៅ។

ក៖ ហ្វ! គាត់បានស្លាប់លឿនមែនទែនអ៊ុំ។

ខ៖ ចាស! លឿនណាស់គាត់ស្លាប់តែពីឬថ្ងៃទេ។ គាត់ឈើបានតែមួយថ្ងៃគត់!

ក៖ ចាសចាស!

ខ៖ ហើយគាត់ឆ្លងបានតែមួយយប់នឹង! ហើយស្អែកឡើងគាត់ខូចប៉ុនដោយ។

ក៖ ចាសអ៊ុំ!

ខ៖ គាត់ខូចនឹង! ហើយគ្មានតៅមើលគាត់អីទាន់?!

ក៖ ចាសអ៊ុំ!

ខ៖ គាត់ឡើងស្លរឈាមពីផ្ទះហើយនឹងបានយកគាត់ទៅ។

ក៖ ជាអ៊ុំ!

ខ៖ មិនហាត់អ្នកណា! ហើយអ្នកជិតខាងគ្មានអ្នកណាដឹងថាគាត់ស្លាប់ផង!

ក៖ ចាសអ៊ុំ! ដោយសាតែគាត់ស្លាប់លឿនពេកហ្វអ៊ុំ!

ខ៖ ចាសចាស! មិនមានអ្នកណាដឹងថាគាត់ស្លាប់ណា។ បើពេលល្ងាចឡើងប្រហែលម៉ោងប្រាំម៉ោងប្រាំមួយនឹងយកគាត់ទៅពេទ្យហើយគាត់ស្លរឈាមបាត់ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ មានស្អីទៀត។

ក៖ អញ្ចឹងតើម្ដាយរបស់អ៊ុំគាត់ឈើតែរោគទឹមនោមផ្អែមមួយទេន៍អ៊ុំ? ឬក៏តើគាត់មានឈើរោគអ្វីផ្សេងពីនឹងទៀតដែលឬក៏អត់ទេ?

ខ៖ ចាស! គាត់ឈើរោគតែមួយនឹងឯង។ ហើយក៏គាត់ឈើរោគផ្សេងទៀតទៅ! ដូចជាលើសឈាមលើសអីទៅ! ហើយគាត់ងងឹតភ្នែកមើលអីមិនឃើញ។ ហើយគាត់ដូចគ្នាតែនឹងខ្ញុំដែលនឹងរោគទឹកនោមផ្អែមហ្វ! អ៊ុំមើលអីមិនឃើញទេស្រវាំង! មើលគេមិនឃើញតែ។

ក៖ អូ! តើអ៊ុំកើតទឹកនោមផ្អែមដែលមែន?

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំកើតនឹងយូរហើយនៅអ៊ុំ?

ខ៖ អ៊ុំកើតបានពីរឆ្នាំហើយទាំងឆ្នាំនេះ! ពីរឆ្នាំទាំងឆ្នាំនេះឯង។

ក៖ ហ៊ី!

ខ៖ ទឹកនោមផ្អេកមើលអីមិនឃើញទេ! ដល់ពេលដល់ខែបើកថ្នាំដល់ខែបើកថ្នាំ។

ក៖ អូ! អារោគទឹកនោកផ្អែកនឹងពេលកើតស្រវាំងភ្នែកដែលមែនអ៊ុំ?

ខ៖ ចាស! ស្រវាំងភ្នែក។ ហើយមើលអីមិនឃើញទេ។

ក៖ ហើយតើមានអស់កំលាំងដែលអត់អ៊ុំ?

ខ៖ ចាសអស់! អស់កម្លាំង។

ក៖ ហ៊ី!

ខ៖ ហើយព្រលឹមឡើងអញ្ចឹងហាវទៅហើយគ្មានកម្លាំងទេ! អត់មានសោះ។

ក៖ ចាសចាស! អញ្ចឹងត់ពេទ្យមានថ្នាំពូវកម្លាំងអីអោយអ៊ុំលេបដែលអ៊ុំ? ហើតតើឥឡូវនេះអ៊ុំមានប្រើថ្នាំដែលអត់?

ខ៖ ឥឡូវនេះអ៊ុំប្រើដែលតើ! ប្រើអាថ្នាំទឹកនោមហ្វ!

ក៖ ចាស!

ខ៖ ទៅដល់មួយខែគេជួសឈាមមួយដង! ឡើងចុះឡើងចុះពេញតែនឹងឯង។ ថ្ងៃណាទៅជយសឃើញ២០០ទៅហើយថ្ងៃណាទៅជួសឃើញ២០០ជាងទៅ។

កៈ ចាអ៊ុំ!

ខៈ អាឈាមយើងហើយនឹងទឹកនោមយើងនឹង។ ២០០ជាងជូនណាទៅចុះ១៨០! ហើយជូនណាទៅឡើង២០០ជាងទទៅ។ វាមានចុះមានឡើងហើយវាអត់មានដាច់ទេអាពោគទឹកនោមផ្អែមនឹងហ្ន។

កៈ ចាសអ៊ុំ! ហ៊ឺ!

ខៈ ហើយបើយើងមិនមើលមិនលេប! ចុះហែកទឹកនោមយើងចុះមួយយប់មួយយប់វាស់ពញរឹក។

កៈ ហ៊ឺ ចាសអ៊ុំ!

ខៈ ហើយឡើងពេញៗខោ! អញ្ចឹងបានខ្ញុំស្រកសាច់នឹង!

កៈ ចាសនឹងហើយ! ខ្ញុំឃើញអ៊ុំពីមុនរាងមានសាច់ហាស់!

ខៈ ចាស!

កៈ អានេះ! ពោគនឹងមិនមែនតពូជទេណាហីអ៊ុំ? ដោយសារតែម្ដាយរបស់អ៊ុំគាត់កើតពោគទឹកនោមផ្អែមនឹងដែល?!

ខៈ វាមិនតពូជទេ!

កៈ ចាស!

ខៈ ដោយសារតែឥឡូវនេះជាតិគីមីវាខ្លាំង។

កៈ ចាសអ៊ុំ!

ខៈ ជាតិគ៍មីនឹងវាខ្លាំង! ហើយគ្មានតពូជតស្អីទេ!

កៈ ចាសអ៊ុំ!

ខៈ ទោះពីនៅសង្គមពីដើមមើល, គ្មានអ្នកណាម្នាក់មានទឹកនោមផ្អែម?

កៈ ចាសអ៊ុំ!

ខ៖ គឺគ្មានទេ!

ក៖ ទើបតែមកឥឡូវ?

ខ៖ ចាស! វាទើបតែមកៀឪឡូបនេះទេ។

ក៖ ចាសចាស!

ខ៖ ទើបតែឥឡូវនេះឯង។

ក៖ ចាសអ៊ុំ!អញ្ចឹងអ៊ុំត្រូវញាំអីអោយតមតិចហើយណាអ៊ុំ!

ខ៖ អ៊ុំវាមិនដឹងថាត្រូវតមអ្វីទេ! វាអត់មានអីហូប។

ក៖ ចាសអ៊ុំ!

ខ៖ អត់មានអ្វីហូបមិនដឹងថាត្រូវតមស្អី?

ក៖ ចាសហា! អញ្ចឹងតមវាអត់កើតទៀតណា!

ខ៖ ចាស! ហើយបើសិនជាយើងតមពកទៅវាអត់មានកម្លាំងទេ។

ក៖ ចាសអ៊ុំ!

ខ៖ អត់មានកំម្លាំងទេ!

ក៖ ហ៊ឺ!

ខ៖ ពេទ្យគេអោយយើងតមពេក។ ហើយពេលដែលយើងចង់ហូបអីយើងហូបតិចទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយដូចអារឿងបង្អែមអីគេអោយហូបបានប្រាំរយអីទៅ។

ក៖ ចាសអ៊ុំ!

ខ៖ បាន! បានប៉ុននឹង។

ក៖ ចាស! តិចតួចៗ កុំអោយអ៊ុំអស់កម្លាំងពេកទៅណាស់!

ខ៖ អ៊ុំងើបឡើងហារ! រិលអញ្ចឹងហាស់?

ក៖ ចាស!

ខ៖ ហើយហឹងស្លឹកច្រច្រៀករើង! ហើយថ្ងៃណាទៅរិលៗចង់ដួល!ហើយដល់ពេលរួចទទៅអង្គុយទៅ។

ក៖ ចាសអ៊ុំ! នឹងហើយដោយសារតែយើងខ្សោយ!

ខ៖ ចាសនឹងហើយខ្សោយ!

ក៖ ហើយដោយសារតែអ៊ុំខ្វះជាតិស្ករ។ ហើយបើយើងញាំផ្អែមពេកក៏អត់បានដែលអារោគនឹងហ្ង!

ខ៖ ចាសអត់បានដែល!

ក៖ ចាស!

ខ៖ ជាតិគេហៅថាស្អីទេ? សន្លាក់!

ក៖ អាស៊ីតមែនអ៊ុំ?

ខ៖ ចាស! ជាតិអាស៊ីត។ អាស៊ីក៏ឡើងដែល។ ឡើង, ឡើង៧០%ហ្ង!

ក៖ អូ្ង! ចឹងអ៊ុំកើតរោគអាស៊ីតទៀត?

ខ៖ ចាស! ឡើងុ, ឡើងខ្ញុំខ្សោយកាច់ដៃកាច់ជើងឡើងក្រងៃងក្រង៉ង់។

ក៖ អូ្ង!

ខ៖ ខ្ញុំក្មានដឹងអីទេ! រួចទៅក៏កូនគេយកខ្ញុំទៅពេទ្យទៅ! ហើយពេទ្យគេមិនចឹងហ៊ានមើលខ្ញុំផង។

ក៖ មិចបានអញ្ចឹងអ៊ុំ?

ខ៖ ដោយសារតែអ៊ុំមានរោគទឹកនោមផ្អែមផង?

ក៖ ហើយនឹងអាស៊ីត?!

ខ៖ ចា! ហើយនឹងអាស៊ីតផង! ហើយកាលនឹងមានគ្រុនឈាមផង។

ក៖ អូ!

ខ៖ គ្រុនឈាមហាស់?

ក៖ ចាអ៊ុំ!

ខ៖ ចា! ហើយអាស៊ីតវាឡើងហើយ, ហើតទឹនោមផ្អែម, គ្រុនឈាម! ហើយ? ទាំងអស់ប្អូនមិខ។

ក៖ វាយ!

ខ៖ ហើយនឹងពោះវៀន។

ក៖ អូស!

ខ៖ នឹងហា! កាលនឹងខ្ញុំឈើមិនចេះតិចទេ! ហើយខ្ញុំគិតថាខ្ញុំងាប់ហើយតើ! តែបានកូនគេដឹកយកទពេទ្យ។

ក៖ វាយ! អ៊ុំឈើពោគច្រើនមុខមែនទែន! ហើយពោគដែលអ៊ុំឈើតទាំងអស់នឹងសុទ្ធតែពោគគ្រោះថ្នាក់ទាំងអស់ទៀត។

ខ៖ ចាគ្រោះថ្នាក់ណាស់។

ក៖ ចាចា!

ខ៖ ច្រើន។

ក៖ ចា! អញ្ចឹងតើអ៊ុំឥឡូវបានប៉ុននេះវិញដូចថា!

ខ៖ នឹងប៉ុននេះលើកនេះនៅគ្រាន់ទេ! បើលើកមុនដែលខ្ញុំមិនទាន់បានចូលព្រះវិហារហាស់?

ក៖ ចាអ៊ុំ!

ខ៖ ខ្ញុំថា! ខ្ញុំងាប់ហើយតើ។

ក៖ ហ៊ឺ!

ខ៖ ខ្ញុំអត់មានដឹងខ្លួនទេ!

កៈ កាលដែលអ៊ុំអត់ទាន់បានចូលព្រះវិហារហើ?

ខៈ ចាចា! នៅ គេដឹកយកខ្ញុំទៅពេទ្យហោក។

កៈ ចា!

ខៈ ហើយគេថាខ្ញុំកាកូកាកាយពេញពេទ្យ! ហើយពេទ្យគេចាប់មិនឈ្នះហើយគេមិនចង់អោយខ្ញុំនៅ។

កៈ ចាស!

ខៈ ខ្ញុំអត់ដឹងខ្លួនថាខ្លួនឯងនឹងវាចឹងសោះ។មើលទៅហើយមើលឃើញគេដើរទៅរហូត! ដូចោឡើងឋានសួគចឹងចេះតែទៅហើយ។មើលអត់ឃើញអត់ដឹង មើលឃើញតែខ្លួនឯងអត់ដឹងខ្លួន។

កៈ ចាស!

ខ គេ! គេថាមិនដឹង។

កៈ ចាស!

ខៈ ហើយខ្ញុំចេះតែមើលទៅ! ហើយមើលទៅឃើញតែគេដើរសន្លឹម!ដាច់កន្ទុយភ្នែកទៅអត់មានដឹងខ្លួនដឹងប្រាណអីអត់។ ដូចតាគោអញ្ជឹងឯង, ឃើញអត់?

កៈ ចាសអ៊ុំ!

ខៈ តាគោគាត់ចឹងហាស់។

កៈ ចាសនឹងហើយអ៊ុំ! តែឥឡូវខួមឮសួរថាគាត់បានគ្រាន់ហើយ។

ខៈ បានគ្រាន់ហើយ។

កៈ ចាសអ៊ុំ!

ខៈ គាត់អាចហូបបាយបានអីបានហើយ។ គ្រាន់តែដើរមោនទាន់ទាន់រួច។

កៈ ចាអ៊ុំ!

ខ៖ គេដាក់គ្រែមួយអោយគាត់រុញទៅ! រុញមក។

ក៖ ចាស! ឈើអីក៏មិនស្រួលដែលអ៊ុំអោយតែពាក្យថាឈើមួយម៉ាត់ហើយ។

ខ៖ ចា! ខ្ញុំកូនយំពេញផ្ទះហើយតើកាលមួយហ៏កនឹង។

ក៖ ចាសអ៊ុំ!

ខ៖ កូននាំគ្នាមកសាវាសាវាមកមួយៗមកពីថៃហោ! បាក់ទ័ពមកមកមើលខ្ញុំ។

ក៖ ចាសអ៊ុំ!

ខ៖ ម្នាក់២នៅនេះគេចាអាស់ចាអូម! គេល្បីតើ! គេល្បីដល់ពេលដែលខ្ញុំបានដើរកើតគេថាហ៊ុរស់ហើយ?ជាហើយហា? មិនដឹងទេមិនដឹងថាជាឬមិនជាផង។ ខ្ញុំមិនតង់ដឹងថាខ្លួនឯងនឹងឈើអីផង។

ក៖ ចាសអ៊ុំ!

ខ៖ អត់ដឹង!

ក៖ អូ! អ៊ុំអត់ដឹងថាខ្លួនឯងឈើអីផងកាលនឹង?

ខ៖ ចាសអត់!

ក៖ អ៊ុំបាត់បង់ស្មារត្តីឬក៏យ៉ាងម៉េច?

ខ៖ វាបាត់!វាមិនដឹងខ្លួន។

ក៖ អូ! មួយនឹងគេហៅថាសន្លប់ហាស់។

ខ៖ ចាគ្រាន់តែដឹងថាអត់ដឹងខ្លួន។

ក៖ ចាសចុះអត់ដឹងខ្លួននឹងក្នុងរយៈពេលប៉ុន្មានអាទិត្យដែលអ៊ុំ?

ខ៖ អត់ដឹង! ឮគេថាមួយអាទិត្យ។

ក៖ អូ! ចឹងអ៊ុំសន្លប់នឹងតែមួយអាទិត្យទេអ៊ុំនោះ?

ខ៖ ចាស! កូនគេថាតេមួយអាទិត្យហើយពេលដែលគេដឹកអាទះសេះមក! អូអាតុតុគេកំពុងតែដឹកមកផ្ទះក៏មិនដឹងថាដឹក។

ក៖ ហ៊ឺ!

ខ៖ គេចាប់ខ្ញុំចង! កុំអោយខ្ញុំរើកុំអោយខ្ញុំនឹងលោតធ្លាក់ពីលើតុតុក៏មានដែល។

ក៖ ចាសអ៊ុំ!

ខ៖ ហើយខាំកូនក៏មានដែល!

ក៖ អូស!

ខ៖ ខ្ញុំហាស់?

ក៖ ម៉េចបានអញ្ចឹងអ៊ុំ?

ខ៖ ដោយសារតែអតដឹង។

ក៖ អត់ដឹង?

ខ៖ ចាស! ហើយកូនខ្ញុំអាប្រុសមួយនោះវាថា៖ ម៉ាក់ឯងអោយតែឃើញមុខខ្ញុំមិនបានទេចង់តែរកខាំខ្ញុំ។

ក៖ អូ!

ខ៖ ខ្ញុំអត់ដឹងខ្ញុំគ្មានដឹងទេ, គ្មានដឹងគ្មានអីទេ។ អញ្ចឹងមនុស្សឈើហាស់?

ក៖ ចាសអ៊ុំ! ហើយដល់ពេលដែលយកមកផ្ទះវិញអញ្ចឹងអត់មានពេទ្យមើលទេ?

ខ៖ មានពេទ្យឯណាមើលខ្ញុំ! ខ្ញុំស្រោចទឹក។ និមន្តគ្រូកេមកស្រោចទឹកអោយ។

ក៖ អូ!

ខ៖ និមន្តគ្រូអោយគេមកស្រោចទឹកហើយនឹងនិមន្តលោក។

ក៖ ចាស!

ខ៖ ហើយដលពេលដេលគេដាក់ថ្នាំទៅ។ ដល់ពេលដែលងើបពីសន្លាប់ទៅមើលគមើលឯង!

កៈ ចាស!

ខ មិមដឹងថាគេនឹងអ្នកណាឬអ្នកណី។

កៈ ចាសអ៊ុំ!

ខៈ ដល់ពេលបានដាក់សេរ៉ូមដាក់អីត្រូវទៅ។ ហើយបនលោកមកស្រោចទឹកអោយពីរបីដង។

កៈ ចាសអ៊ុំ! អញ្ចឹងម៉លតាមរបៀបរសប់ខ្មែរយើង?

ខៈ ចា! របៀបខ្មែរ។អានេះដូចថាៈ យើងគេចងចំណាងយើងហាស់។

កៈ ចាសអ៊ុំ!

ខៈ អញ្ចឹងហាស់!គេមិនអោយយើងដឹងគេមនអោយយើងឮហាស់?!

កៈ ចាស! មួយនឹងគេធ្វើអំពើអ៊ុំឬក៏យ៉ងម៉ែចដែលេ?

ខៈ អត់ទេគេថាខោច។

កៈ ខោចកាច់អញ្ចឹង?

ខៈ គេធ្វើ!

កៈ ខោចធ្វើអញ្ចឹង?

ខៈ ចា!

កៈ ហ៊ឺ!

ខៈ ចឹងតាំចងពីនឹងមកក៏បានជាមកដល់សព្វថ្ងៃនឹងហាស់! ក៏បានទៅព្រះវិហារបានប៉ុន្មាននឹង! អាកូនខ្ញុំអាពៅនឹងវាឈើ។

កៈ ចាសអ៊ុំ!

ខៈ ដ់ពេលរួចពីអាពៅដល់ខ្ញុំម្តង!

កៈ ហ៊ឺ!

ខ៖ គ្រុនឈាមគ្រុនពោះវៀនម្តង។

ក៖ ចាស!

ខ៖ ហើយម្នាក់ៗគេផ្អើលថាខ្ញុំមិនរស់ទេកាលនឹងហ្ន៎!

ក៖ ចាសអ៊ុំ!

ខ៖ ហើយមិនដឹងថាសំពត់នកៅឯណាហើយខោនៅឯណាទេ។

ក៖ ចាសអ៊ុំ! អានេះដូច!

ខ៖ ស្រាតននិលននោលអស់! ហើយខ្ញុំថាខ្ញុំឆៀកាលអាម៉ារីកនឹងហ្ន៎?

ក៖ ចាអ៊ុំ! នេះពេលដែលដឹងខ្លួនមកវិញអ៊ុំចម្ងតាទៅ?

ខ៖ ចាស!ពេលែដែលដឹងខ្លួនមកវិញខ្ញុំអត់មានកម្លាំងទេ។ ដូចរស់ម្តងទៀត!

ក៖ អូ!

ខ៖ បានជឿព្រះនឹងឯង!

ក៖ អត់ទេកាលដែលអ៊ុំឈើនឹងអ៊ុំអត់ទាន់ចូលព្រះវិហារទេ?

ខ៖ ចាស! ខ្ញុំឆើនឹងខ្ញុំឈើមុនហ្ន៎?!

ក៖ ចាសអ៊ុំ!

ខ៖ ឈើអាពេលដែលចៅខ្ញុំកើតនឹង! អូឈើនៅពលដែលចៅរបស់ខ្ញុំនៅក្នុងពោះ។

ក៖ ចានឹងហើយអ៊ុំ! អញ្ចឹងនេះដូចថាបព្រះបានប្រទានជីវិតអោយអ៊ុំបានរស់ម្តងទៀតចឹងហាស់?

ខ៖ ចាស!

ក៖ ចាសអ៊ុំ! នេះដោយសារតែពទ្យគេលែងម៉លអ៊ុំហើយ។

ខ ចាសចា! ខ្ញុំជឿហើយព្រះ! បើថាខ្ញុំមិនជឿខ្ញុំទៅធ្វើអី?

កៈ ចាសអ៊ុំ!

ខៈ ចាស! ខ្ញុំជឿ, ដូចថាកាលពីមុនដំបូងខ្ញុំជឿជាមួយកាន់ឡាអីនឹងហាស់?

កៈ ចាសអ៊ុំ!

ខៈ ហើយខ្ញុំចូល! ហើយដលើពេលដែលខ្ញុំចូលទៅខ្ញុំអធិដ្ឋានហើយខ្ញុំមិនចេះទេ។

កៈ ចាសអ៊ុំ!

ខៈ ពេលអធិដ្ឋានបិបឹកអញ្ចឹងទៅ! ខ្ញុំបានឃើញព្រះវិហារមួយយ៉ាងវែងហើយស! កាលនឹងប្រធានប្រុសទេ?

កៈ ចាសអ៊ុំ!

ខៈ អូជាខែលខើរ។

កៈ ចាស!

ខៈ ប្រុសកាលនឹងហូ? ដល់ពេលនេះមកបង្ហាត់ខ្ញុំទៅ! ដល់ពេលហើយទៅខ្ញុំយល់សប់ឃើញស្លៀកសពាក់សបាលយព្រះវិហារឡើងវែងអោយក្រលួតទៅហើយស្ទីស្ទើរប្រុសនឹងគាត់ឈរអញ្ចឹងឯង( អេលខើរ )។

កៈ ចាសអ៊ុំ!

ខៈ ឈរមួយចំហៀងអញ្ចឹងឯង!ដល់ពេលខ្ញុំឈរទៅ, ខ្ញុំបានឃើញផ្លូវហាស់? ឃើញសុទ្ធតែផ្លូវហើយផ្លូវអោយសសុះ។

កៈ ចាសអ៊ុំ!

ខៈ ចាស! ខ្ញុំបានឃើញតែប៉ុននឹងឯង!ដលល់ពេលដេលខ្ញុំពិបាកចៅពេកទទៅក័ខ្ញុំឆប់ទៅ។

កៈ អូ?

ខៈ ហើយចៅរបស់ខ្ញុំពីរបីនោះនឹងមានអី?

កៈ ចាស! អញ្ចឹងអ៊ុំយលល់សប់ឃើញពួកខែលខើរស្ទីស្ទើរនឹងមុនពេលដែលអ៊ុំបានចូលជាសមាជិកទៀត?

ខ៖ ចាសមុន។

ក៖ ហើយក៏មុនដែលអ៊ុំបានស្គាល់ដំណឹងល្អទៀត?

ខ៖ ចាចូលមុន!

ក៖ ចាស!

ខ៖ ហើយគ្រាន់តែចូលបានប៉ុន្មានថកងៃនឹងគេយកថៅមកដាក់អោយមើល! ហើយយំឡាលេឡាទៅ អូសបែកទៅមិនរួចទេ?

ក៖ ហ៊ឺ!

ខ៖ ក៏សំរាកទៅ!ហើយកាលនឹងចូលតាំងពីជំនាន់តាសុនម្លះ១។

ក៖ អូអ៊ុំចូលតាំងពីរអ៊ុំសុនម្លះ?

ខ៖ ចានឹងហើយ! នឹងហើយជំនាន់តាសុនមុននឹង!

ក៖ ចា! អ៊ុំគាត់ចូលបានយូរហើយ។

ខ៖ ចានឹងហើយ! ដល់ពេលរួចហើយទៅគាត់បានឈប់! ហើយដល់ពេលរួចទៅគាត់ទោះបតែទៅវិញទៀត។

ក៖ ចាសអ៊ុំ!

ខ៖ បានចូលទៀត។

ក៖ អញ្ចឹងអ៊ុំបានស្គាល់នៅដមណឹងល្អយូរហើយតែទឹមតែសម្រេចចិត្តទទួលបុណ្យជ្រមុជតឹក?

ខ៖ ចាស! ទឹមតែសម្រេច។

ក៖ ទឹមតែជ្រមុជទឹកឆ្នាំមិននេះដែល?

ខ៖ ចា! ហើយតាគោគាត់បានបបួលខ្ញុំអោយចូលដែលតាគោគាត់ថាចូលទៅមីអូនអើយ។ យើងទៅតែមួយអាទិត្យម្តងមួយអាទិត្យម្តងអោយយើងនឹងបានប្រែរូបថ្មីអោយដឹងអោយឮ។ ហើយកាលនឹងកាត់ចេះតែបបួលខ្ញុំទៅ, ហើយខ្ញុំមិនដែលបានទៅវាយ៉ាប់នឹងកូនពិបាក!

កៈ ចាស!

ខៈ ហើយពិបាននឹងចៅវាគ្មានអីស៊ីរកមកបានមិនឃើញ!

កៈ ចាសអ៊ុំ!

ខៈ ដល់ពេលឆ្នាំនេះទៅខ្ញុំនឹកឃើញព្រះ! ទៅខ្ញុំលហាសើចូលទទៅហើយទៅតែមួយអាទិត្យម្តង។

កៈ អញ្ចឹងតើអ៊ុំជឿថាព្រះបិហាររបស់យើងនេះពិតដែលឬអត់?

ខៈ ចាពិត!

កៈ ចាស! អញ្ចឹងតើអ្វីដែលអ៊ុំស្រីជឿថាដំណឹងល្អរបស់ព្រះយេស៊ូវគ្រិស្ទជាការពិត?

ខៈ ពិត!

កៈ ដូចជាតើអ៊ុំបានទទួលបានបទពិសោធអ្វីខ្លះនៅក្នុងជីវិតរបស់អ៊ុំទើបអ៊ុំជឿថាដំណឹងល្អនៃព្រះ?

ខៈ ពេលដែលខ្ញុំអធិដ្ឋានទៅដូចថាពេលដែលខ្ញុំដើរទៅណាទៅណីអីទទៅមានគេជួយរហូត។

កៈ អញ្ចឹងហ្ហអ៊ុំ?

ខៈ ចាជួយ! អាដែងណាកាលនឹងខ្ញុំយល់សប់ឃើញនេះមែនៈ ខ្ញុំស្រែកអោយជួយខ្ញុំផងមានបុរសម្នាក់មាឌធំដំបងហើយសក់ឡើងរួញអង្គាញ់ដូចអាដែងនេកអ្នកកីឡាកាសចឹងហាស់?

កៈ ជាសអ៊ុំ!

ខៈ ហើយខ្ញុំបានឃើញគេលោតហាក់មកជួយខ្ញុំ! ហើយអាអ្នកដែលដេញចាប់ខ្ញុំនឹងវាចេះតែដេញចាប់ដេញចាប់ខ្ញុំ! តែវាចាប់ខ្ញុំអត់បានទេខ្ញុំរត់ពួន។ ពួនចឹងទៅបានគេមកជួយខ្ញុំរហូតមក។ នឹង

កៈ ចាសអ៊ុំ!

ខ ឃើញ! មាឌធំដំបងដូចកីឡាកាសចឹង។

កៈ ចាសអ៊ុំ!

ខ៖ រូបរបស់វាដូចអាអីគេ? ដែលគេធ្វើដាក់គ្រប់ៗនៅក្នុងខ្លួនហ្ន?

ក៖ ចាសអ៊ំ!

ខ៖ នឹងហើយយើញ។

ក៖ ចាស! អញ្ចឹងអស្ចារ្យមែនអ៊ំព្រះបានធ្វើអាភូតហេតុ។

ខ៖ ចាស!

ក៖ ដូចជាព្រះបានជួយអ៊ំតាមរយៈអោយអ្នកផ្សេងទៀតមកជួយ។

ខ៖ ចាសអោយគេមកជួយ។

ក៖ ចាស!

ខ៖ ហើយខ្ញុំចេះតែរត់ទៅ! ហើយម្នាក់នឹងចេះតែលោកហាក់មកជួយ! ជួយខាងណេះជួលខាងនោះ។ ហើយរត់ពួនទាល់តែជិតគេរកអត់យើញ។

ក៖ ចាសអ៊ំ! នឹងហើយអ៊ំអរគុណាច្រើនដែលបានចែកចាយមួយនឹងជាមួយញុមនៅថ្ងៃនេះ។

ខ៖ ចាចា!

ក៖ ចា! អញ្ចឹងខ្ញុមចង់សួរអ៊ំខ្លះៗ! តើអ៊ំមានចាំធ្វីខ្លះពីជីដូនជីតារបស់អ៊ំទេ? ដូចជាតើគាត់បានបន្សល់ទុកនូវអ្វីដែលល្អៗអោយអ៊ំទេដែលធ្វើអោយអ៊ំចងចាំពីពួកគាត់ដែលទេ?

ខ៖ អត់មានបានចងចាំអីទេ។

ក៖ អត់មានទេ?

ខ៖ អត់!

ក៖ ចាស! ដោយសារតែអ៊ំកើតអត់ទាន់ពួកគាត់តតើមែនទេ?

ខ៖ ចា! អូកើតទាន់។

ក៖ ចាស!

ខ៖ គាត់កើតនៅពង់ហោក! នៅកំពង់ខាងកើតផ្សារកណ្តាល។ នេះអ៊ំវាភ្លចភ្លាំងអស់ហើយ។

កៈ ចាសអ៊ុំ!

ខៈ ចា!

កៈ អញ្ចឹងអ៊ុំអត់មានបានចាំអីពីពួកគាត់ទេ?

ខៈ អត់!

ខៈ ហើយចុះតើឪពុកម្តាយរបស់អ៊ុំវិញ? ឪពុកម្តាយបង្កើតហាស់?

ខៈ ឪពុកម្តាយរបស់ខ្ញុំបង្កើតគេយកពួកគាំត់ទៅសម្លាប់ចោល។

កៈ នៅសម័យ?

ខៈ នៅសម័យប៉ុលពត!

កៈ ប៉ុលពតហ្នអ៊ុំ?

ខ ចា!

កៈ ចាស! អញ្ចញ្ចឹងតើកាលណឹងឪពុកម្តាយរបស់តើពួកគាត់បានធ្វើអ្វីដែលបានជាគេយកពួកគាត់ទៅសម្លាប់ចោល?

ខៈ ពួកគត់អត់មានបានធ្វើអ្វីទេ! មានបានធ្វើអៅផងគ្រាន់ទេធ្វើទាហានហើយនេះអីៗនេះទៅហើយគាតធ្វើស្រែធ្វើចំការ, តែប៉ុននឹងឯង។

កៈ ចាសអ៊ុំ!

ខៈ មានអ្នកោតគាត់! គេចោតគាត់។

កៈ ហ៊ឹម!

ខៈ គេថាយើងធ្វើស្អីៗទៅៗ ក៏គេយកគាត់ទៅ! នោកទៅយកគាត់ទៅសំម្លាប់នៅឯនោកនៅឯកំពង់ព្រះហោក។

កៈ ចាស!នៅកំពង់ពប្រះយើងនេះហោអ៊ុំ?

ខៈ ចាចាស! គាត់ទទៅភ្នួរស្រែហោ!

ក៖ ចាសអុំ!

ខ៖ ទៅភ្នូរស្រែគេធ្វើរតែកាសៀវមួយទេអោយដឹង! ដល់ពេលនេះទៅម្ដាយរបស់ខ្ញុំគាត់ទំនន់អារ៉ុងហោ?

ក៖ ចាសអុំ!

ខ៖ ពូរ៉ុងលក់ទេកអំពៅហោ?

ក៖ ចាសអុំ!

ខ៖ នឹងហើយកំណើតអាមួយនឹង។ ហើយបានវាមួយនឹងមកក៏បែកទៅគេយកគាត់ទៅសម្លាប់ទៅ។

ក៖ ហ៊ឹម!

ខ៖ តែប៉ុននឹងឯង!

ក៖ ចាអុំ!

ខ៖ ហើយដល់ពេលឥឡូវនេះទៅមានកូនចៅក្មួយនៅឯបោះពោធ៏ហោ។

ក៖ ចាស!

ខ៖ នៅបោះពោធ៏បានកូនពីរ។

ក៖ ចាសអុំ!

ខ៖ ចាស! ហើយបងប្អូនប្អូនបីនាក់ហោក!

ក៖ ចាស!

ខ៖ ហើយតើស្គាល់អុំមីអត់?

ក៖ ចាស! ញុមទាល់តែឃើគមុខគាត់ប្រហែលជាស្គាល់គាត់អុំ!

ខ៖ ហ៊ឺ!

ក៖ តើគាត់បានចូលជាសមាជិកដែលតើហីអុំ?

ខ៖ អត់ទេ។

ក៖ អត់ទេន៏អ៊ុំ?

ខ៖ អូម៉ាក់របស់ចាន់ណាហ្វ? ចាន់ណាចូល។

ក៖ ចាអ៊ុំ! បើបងចាន់ណាខ្ញុំស្គាល់តែបើម៉ាក់របស់គាត់ខ្ញុំអតង់ស្គាល់ទេ។

ខ៖ មីងឡុងហោ?

ក៖ អូ!

ខ៖ អ៊ុំឡុងហោ?

ក៖ អូ!

ខ៖ ចា! នឹងបងថ្លៃ។

ក៖ ចាសអ៊ុំ! អញ្ចឹងតើបងប្អូនរបស់អ៊ុំទាំងអស់តើពួកគាត់នៅបាត់ដំបងទាំងអស់គ្នាទេ?

ខ៖ ចា!នៅទាំងអស់។

ក៖ អូខេ! ខ្ញុំស្មានតែពួកគាត់មានគ្រុមគ្រួសារហើយពួកគាត់បែកទទៅនៅផ្សេងចឹងហាស់?

ខ៖ មានមួយនៅបោះពោធ៏, ហើយមួយទៀតនៅខាងក្រោយនេះ។

ក៖ ចាសអ៊ុំ!

ខ៖ តែគាំត់ទៅធ្វើការនៅព្រែកជីកហោ?

ក៖ អូចាសអ៊ុំ។ សុទ្ធតែមានគ្រួសារអស់ហើយ។

ខ៖ ចាសុទ្ធតែមានគ្រួសារអស់ហើយ, ហើយមានកូនមានចៅអីអស់ហើយ!

ក៖ចាសអ៊ុំ!

ខ៖ ហើយងញ្ចឹងកូនទាំងនោះសព្វថ្ងៃនេះតក់តើតតក់តើតអាមួយនោះធ្វើអាពីរក៏ធ្វើសំណង់រកអីមិនឃើញគ្មានស្រែគ្មានចំការអីធ្វើនឹងគេទេ។ ក្តីរំដីមួយដង្កាមចែកគ្នាបានមួយផ្ទះមយយផ្ទះអស់ហើយ។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយ! ហ៊ុម!

ខៈ មានតែមួយផ្ទះមួយផ្ទះនឹងឯង។

កៈ ចាអ៊ុំ! អញ្ចឹងតើអ៊ុំអាចប្រាប់ខ្ញុំខ្លះៗពីម្តាយរបស់បានទេ? ដូចថាតើគាត់ជានារីបែបណា ហើយតើគាត់បានផ្តល់ដំបូលន្មានអ្វីខ្លះដល់អ៊ុំហើយតើគាត់បានជួយស្អីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំចឹហហាស់? តើអ៊ុំអាចប្រាប់ខ្ញុំពីប្រវត្តិរបស់ម្តាយអ៊ុំខ្លះបានទេ?

ខៈ ម្តាយរបស់ខ្ញុំបាន! មានបានធ្វើស្អីបានតែធ្វើស្រែធ្វើចំការនឹង។ មានធ្វើអី។

កៈ ចាសអ៊ុំ!

ខៈ មានតែបានធ្វើស្រែធ្វើចំការតិចតួចនឹងឯង។

កៈ ចាស! អញ្ចញចឹងតើគាត់មានបានបង្រៀនអ្វីខ្លះដល់អ៊ុំដែលពេលអ៊ុំធំឡើងមករហូតដល់ធំដឹងក្តីប៉ុននេះ?

ខៈ គាត់បានបង្រៀនខ្ញុំអោយទៅធ្វើការរកស៊ីហើយធ្វើនំលក់នៅអីទៅ។

កៈ ចាសអ៊ុំ!

ខៈ លក់នំលក់អីទៅដើម្បីចិញ្ចឹមជីវិត។

កៈ ចាស!

ខៈ មានតែប៉ុននឹងឯងមានតែប៉ុននឹងឯង។

កៈ ចាសអ៊ុំ! អញ្ចឹងតើម្តាយរបស់អ៊ុំគាត់ធ្លាប់ជាអ្នករកស៊ីដេលមែន? ក្រៅពីការងារធ្វើស្រែចំការហាស់? គាត់លក់ដូរហេះ?

ខៈ គាត់លក់! ដែលធ្វើនំអោយខ្ញុំលក់ទៅ, ហើយខ្ញុំជាអ្នកដើរទូលលក់ទៅ។

កៈ ចាសអ៊ុំ១

ខៈ ដល់ពេលដែលខ្ញុំអត់ពីគាត់ទៅ! ខ្ញុំដើររកស៊ីកម្មករទៅ។

កៈ ចសអ៊ុំ! តើម្តាយរបស់អ៊ុំតើកាត់ចេះធ្វើនំអ្វីខ្លះដែលនំខ្មែរយើងហាស់អ៊ុំ?

ខៈ នំខ្មែរយើងដូចជាៈ នំបុកបែកនំល្ពៅ, នំអន្សមហើយចេកចៀន, ធ្វើបបរលក់ទៅហើយតែប៉ុននឹងឯង។

កៈ ចាស! គាត់ចេះច្រើន!?

ខៈ ចាស!

កៈ ហើយគាត់បានបង្រៀនអ៊ុំបីរប្រៀបធ្វើនំហើយនឹងបបរទាំងអស់នឹងដែលមែនអ៊ុំ?

ខ ចាចា! គាត់បង្រៀនខ្ញុំតើ។ ខ្ញុំដឹងតើ។

កៈ ចាសអញ្ចឹងអ៊ុំ! ឥឡូវនេះអ៊ុំអត់ធ្វើការងារអីទេន៍អ៊ុំ?

ខ ខ្ញុំមិនមានធ្វើការអីកើតទេសព្វថ្ងៃនេះហ្ន! ទៅណាក៏មិនរួចដែល។

កៈ ចាស!

ខៈ បើទៅទៅចោលចៅ

កៈ ហ៊ឹម!

ខៈ ហើយខ្លួនឯងនឹងកផវាមិនស្រួលផង។

កៈ ចាសចា!

ខៈ ចា! វាអត់ស្រួយល!

កៈ ចាសអ៊ុំ! អញ្ចឹងកូនចៅរបស់ហាស់តើពួកគាត់មានចេះធ្វើនំខ្មែរអីដូចអ៊ុំដែលទេ?

ខៈ ចេះ! តែអត់ដែល។

កៈ ចាស!

ខៈ ធ្វើ! ធ្វើលក់។

កៈ ចាស។

ខ៖ ធ្វើលក់, ហើយដើរលក់ទៅ។

ក៖ ចាស!ប៉ុន្តែពួកគាត់អត់ចេះធ្វើទេ?

ខ៖ ចាស! បើធ្វើនំអន្សមអីចេះវិចធ្វើបានតិចតួច!

ក៖ ចាស!

ខ៖ ចេះតែបង្ហាត់ទៅៗនំអន្សមខ្មោរនំអន្សមបេកអីចេះតែបង្ហាត់ៗទៅ។

ក៖ ចាស!

ខ៖ ធ្វើបង្អែមបង់អីខ្លះទៅបេកខ្ទះចេកអីចេះតែធ្វើទៅ។

ក៖ ចាសនឹងហើយអ៊ុំ! អញ្ចឹងតើអ៊ុំមានកូនចៅរក៏បងប្អូនសាច់ញាតិណាដែលពួកគាវ់នៅក្រៅប្រទេសដែលអ៊ុំ?

ខ៖ អ៊ុំអត់!

ក៖ អត់មានទេណាស់?

ខ៖ អត់!ខ្ញុំអត់មាន។

ក៖ ចាស! អញ្ចឹងបងប្អូនទាំងអស់ពួកគាត់នៅស្រុកខ្មែរយើងទាំងអស់?

ខ៖ ចាស!

ក៖ អញ្ចឹងអ៊ុំ!

ខ៖ ចាស!

ក៖ តាំងពីអ៊ុំដឹងក្ដីមកតើអ៊ុំមានដែលបានធ្លាប់ទៅកវៅប្រទេសនឹងគេដែលអត់?

ខ៖ អត់ទេ! ខ្ញុំមិនដែលបានទៅណាទេ! គ្រាន់ទេបាត់ដំបងខ្ញុំស្គាល់មិនទាន់សព្វផងនឹង។?

ក៖ ចាសអ៊ុំ!

ខ៖ គ្រាន់តែផ្សាររោងល្ខោន! មិនដឹងថាឯណាផ្សាររោងល្ខោន? ឯណាផ្សារទួលតាឯកអី?

កៈ អូអ៊ុំអត់ដែលបានទៅដល់នឹងទេ?

ខៈ អត់ដែលស្គាល់!

កៈ ចាស!

ខៈ ទៅមែនកាលខ្ញុំធ្លាប់រែកអ៊ីវ៉ាន់ទៅលក់។

កៈ អូ!

ខៈ ខ្ញុំរែក! លក់ដូងលក់ចេកអីនឹងទៅដល់ផ្សារពោងល្ហោនអីនឹង។

កៈ អ៊ូ! អ៊ុំរែកបានឆ្ងាយណាស់អ៊ុំ!

ខៈ អ៊ូ! កាលនឹងខ្ញុំគ្មានស្អីជឹកទេ! គ្មានស្អីឌុបទេ, ដើរទៅដើរមករែកមួយអង្គរ៉េកមួយអង្គរ៉េកនឹង ទៅហើយបានបួនប្រាំរៀលនឹងអរចង់ដាច់ខ្យល់ហើយ! ចំណេញហើយ។

កៈ ចាសអ៊ុំ!

ខៈ ដូងមួយបីរៀលពីររៀលយកមួយអង្គរែកមួយអង្គរែកនឹងទៅហើយ។

កៈ ចាស!

ខៈ ហើយរែកទៅយកទៅអោយមួយហើយ!

កៈ ចាស!

ខៈ ហើយជួកកាលទៅបាន៩០០០រៀលទៅមកវិញហើយ។

កៈចាស!

ខៈ អរណាស់បានមកវិញយកមកអោយម្ដាយទៅ!

កៈ អូ! កាលនឹងម្ដាយរបស់អ៊ុំគាត់នៅ?

ខៈ ចា! កាលនឹងម្ដាយខ្ញុំគាត់នៅ។ រែកទៅផ្សារទួលតាឯកទៅផ្សារពោងល្ហោងទៅ។

កៈចាស!

ខ៖ ប៉ុន្តែសព្វថ្ងៃនេះមនដឹងថាផ្សាររោងល្ខោននៅឯណាទេ? អត់ដឹង!មិនដឹងថាទៅរកនៅណា។

ក៖ ចាសអ៊ុំ! ឥឡូវនេះខ្លាយទៅជាបុរីអីអស់ហើយ។

ខ៖ ចាស! ខ្លាយទៅជាបុរីអរអីអស់ហើយ! កលាដែលអ៊ុំនៅរ៉ែកលក់នៅនឹង! ពេលដែលអ៊ុំជួបនឹងអ្នកពិការវាសុំយើងជូនកាលទៅវាយកដូចរបស់យើង!

ក៖ ហ៊ឹម!

ខ៖ ហើយយំឡាហែមឡាហាមទៅ! ហើយបើវាយកតែមួយអស់បាត់ហើយ! បានអីចំណាញ់?

ក៖ ចាសអ៊ុំ!

ខ៖ ចា! បានអីចំណាញ់។ ជូនណាយកប្រឡាចគ្នាទៅ! ហើយក៏យំឡាហែមឡាំហាមទៅ។ អាអ្នកដែលពិការវារៃយើងយកទៅដោយសារតែយើងមិនអោយលុយវា។

ក៖ ចាសអ៊ុំ!

ខ៖ ហើយអោយអ៊ុំអោយលុយទៅពួកវាឯណាយើងលក់បានលុយតែតិចតួចនឹង!?

ក៖ ចាសអ៊ុំ!

ខ៖ ហើយបានស្អីបានលុយឯណាយកមកអោយម៉ែឪនៅផ្ទះ? មនុស្សកកោក។

ក៖ ចាសនឹងហើយអ៊ុំ!

ខ៖ អ្នកខ្លះទៅគេជួយទៅ! អ្នកជិតនៅខាងនឹងដូចថា, ជាអ្នកដែលដើរយកប៉ាស៊ីនឹងគេជួយទៅ! គេជួយថាអោយនឹងបានឈប់ទៅ។ អ្នកគ្នាទៅទៀតហាស់ហើយគេសុំមិនអោយយំទៀតហាស់បោកបោះអីវ៉ាំន់ចចូលទៅនឹងអាទឹកនឹងខូចខាតរបស់អស់ទៅទៀត។

ក៖ ចាសអ៊ុំ!

ខ៖ កាលនឹងវាវេទនាណាស់សព្វប់សព្វយ៉ាង។

ក៖ ចាសអ៊ុំ!

ខ៖ ចាស! មួយអង្គរ៉ែកអីបានទៃបួនប្រាំរៀលអី។

កៈ ចាសអ៊ុំ! កាលណឹងអ៊ុំទៅលក់នឹងតើអ៊ុំដើរពីផ្ទះទៅផ្សាររោងល្ខោនមែន?

ខៈ ចាដើរទៅទិញយកទៅលក់នៅវត្តតាមិមនេះនឹងហ្ម?

កៈ ចាសអ៊ុំ! ហើយចេញពីនឹងទៅ?

ខៈ ហើយទៅរ៉ែកឆ្លងស្ពានរទេះភ្លើងហោក! ហើយឆ្លងស្ពានរទេះភ្លើងនឹងហើយទៅផ្សារលើយើងនឹង?

កៈ ចាសអ៊ុំ!

ខៈ ហើយទដល់ផ្សារលើយើងហើយចេះតែទៅទៀតទៅ! ទៅតតែដល់ផ្សារទួលតាឯកផ្សាររោនល្ខោនអីទៅចេះតែទៅទៅ។ ហើយចេះតែរ៉ែកទៅម៉ោងដប់ទៅ១១បានមកដល់ផ្ទះវិញ។

កៈ ចាសអ៊ុំ!

ខៈ ហើយដល់ពេលដែលមកវិញដើរមក! ជួនណាទៅទិញម៉្យៅស៊ុបមកអាម៉្យៅស៊ុបតូចៗគេបិទហ្ម?

កៈ ជាសអ៊ុំ!

ខៈ គេបិទនឹងក្រដាសនឹងមកហើយទិញត្រីនឹងបួនរៀលទៅ។

កៈ អាបួនរយលុយខ្មែរយើងនឹងមែនអ៊ុំ?

ខៈ អាបួនកាក់យើងនឹងហាស់?

កៈ អូ!

ខៈ អាពីរកាក់បូកាក់នឹងហាស់?

កៈ អូចាស!

ខៈ កាលនឹងហាស់!

កៈ គេចាយកាក់កាលនឹង?

ខៈ ចាស! ក្មួយឯងបែបមិនស្គាល់ទែសម៉យនេះហ្ម?

កៈ ចាសអត់ស្គូលល់ទេ។

ខៈ អត់ស្គាល់ទេប្រាក់កាក់ហ្វ!

កៈ ចាសខ្ញុំអត់ស្គាល់មែនតើអ៊ុំ។

ខៈ គេចាយប្រាំកាក់ពីរកាក់! ឥឡូវនេះមានមួយរៀលពីររៀលហើយ! ហើយមានប្រាំរៀល! ពីដើមអត់ទេក្រដាសខៀវៗហោ? លុយពេលនឹង។ តែឥឡូវនេះបាត់អស់ហើយ។

កៈ ចាសអ៊ុំ! លែងមានមែនតើឥឡូវអ៊ុំ!

ខៈ មានអ្នកខ្លះគែនៅទុក! គេទុកអោយកូនមើល។

កៈ ចាសអ៊ុំ!

ខៈ ខ្ញុំទាំន់! ពីដើមខ្ញុំទាំន់ករដាសពីសង្គមក្រដាសក្អមក្រដាសគោ។

កៈ ចាសអ៊ុំ!

ខៈ ក្រដាសគោ, ករដាសក្អម, ក្រដាសស្អីនឹងទាន់!

កៈ ចាសអ៊ុំ!

ខៈ ដល់ពេលមកដល់ឥឡូវនេះវាអស់ហើយ។

កៈ ចាស! នឹងហើយអ៊ុំ។

ខៈ ចាស!

កៈ អញ្ចឹងតើអ៊ុំអាចប្រាប់ខ្ញុំពីជីវិតរបស់អ៊ុំហាស់! ពីជីវិតរបស់អ៊ុំពេលដលអ៊ុំធំឡើងធំឡើងយ៉ាងដីចម្តេចដែល?

ខៈ ខ្ញុំហ្វ? កើយមកវេទនាណាស់! កើតមកទំរាំតែរស់រានមានជីវិតមានកូនមានចៅអីណឹងរហូតមកដល់ឥឡូវនេះគឺវេទនាណាស់។

កៈ ចាស!

ខៈ មិនដែលស្រួលមិនដែលសប្បាយទេ! ខ្ញុំហ្វ។

កៈ ចាសអ៊ុំ!

ខៈ កំសត់កំរណាស់ដើរប៉ះស្លឹកអំពិលដើរប៉ះស្លឹក, ស្លឹកត្រូយត្រកួនអីទៅ! ហើយប៉ះកញ្ចែតប៉ះអីខ្លះទៅប៉ះសព្វគ្រប់! ទួលទៅរែកទៅ។

កៈ ចាសអ៊ុំ!

ខៈ ហើយមកវិញទិញអង្ករយកមកអោយម៉ែមកអោយកូនទៅ។

កៈ ចាសអ៊ុំ!

ខៈ ហើយឡើងប៉ះស្លឹកអំពិលប៉ះអីអាយាស់អស់ហើយដៃជើង! គ្មានសល់ស្អីទេ។

កៈ ចាសអ៊ុំ!

ខៈ ចាស! ហើយដល់ពេលដែលចាស់ខ្លួនហើយនៅតែវេទនាទៀតខ្ញុំហ្ន!

កៈ ហ៊ឹម!

ខៈ នៅតែវេទនានៅតែពិបាក! ប៉ុន្តែដល់មើលដល់តែគិតទៅ, យើងវាមានកម្មពីជាតិមិនមក។

កៈ ចាសអ៊ុំ។

ខៈ កម្មពីជាតិមុនមករហូតដល់យើងអស់កម្មបានយើងឈប់វេទនា។

កៈ ចាសអ៊ុំ!

ខៈ ខ្ញុំកម្មណាស់!

កៈ ចាស! អញ្ចឹងអ៊ុំបានធំឡើងមកជីវិតរបស់អ៊ុំពិបាករហូត!

ខៈ ចាស! ពិបានរហូត។

កៈ ចា! អញ្ចឹងកាលអ៊ុំនៅពីក្មេងរហូតដល់អ៊ុំដឹងក្តីតើអ៊ុំមានបានទៅសាលារៀនអីនឹងគេដែលឬអត់?

ខៈ ទៅសាលាទៅ! តែរៀនអត់ចេះ។

កៈ អូ!

ខ៖ រៀនអត់ចេះទេ! ថាខំខំរៀននឹងណាស់ដែលតែនៅតែរៀនអត់ចេះ។ មិនដឹងថាខួរក្បាលស្អី?

ខ៖ ចាសអ៊ុំ!

ខ៖ ព្រលឹមឡើងទោរៀនហើយ!ហើយគ្រូគេចេះតែបង្ហាត់អោយឡើងអានឡើងអី! អត់ដាក់នៅមុខភ្លេចអាក្រោយ!, ហើយដាក់អាកពោយភ្លេចអាមុខ។

ក៖ ហ៊ឹម!

ខ៖ នឹងវាអត់ឃើញ។

ក៖ ចាស! កាលណឹង?

ខ៖មិនដឹងថាយ៉ងម៉េច?

ក៖ កាលនឹងដោយសារតែអ៊ុំគិតច្រើនពេកក៏មិនដឹង?

ខ៖ ចា!

ក៖ ឬមួយក៏អ៊ុំគិតពីជីវភាពរបស់យើងទើបធ្វើអោយអ៊ុំរៀនអត់ចូលឬក៏យ៉ាងម៉េច?

ខ៖ ដូចជាមិនសូវគិតទេ។

ក៖ ជាសអ៊ុំ!

ខ៖ មិនសូវគិតទេ! ខំរៀនដែលគ្រូគាត់ខំបង្ហាត់យើងដែល! ហើយយើងក៏ខំដែលវានៅតែអត់ចេះ។

ក៖ ចាសអ៊ុំ!

ខ៖ អត់ចេះ! អត់ចេះប្រកបអត់ចេះអានមិនដឹងថាម៉េច?

ក៖ ចាស!

ខ៖ ដូចថាគិតវាអត់ចេញហាស់?

ក៖ ហ៊ឹម! នឹងហើយអ៊ុំ! ប៉ុន្តែអ៊ុំបានរៀនដល់ថ្នាក់ទីប៉ុន្មានដែលកាលនឹងអ៊ុំ?

ខ៖ អ៊ុំរៀនដល់ថ្នាក់ទីបួន!

កៈ អូ! អ៊ុំបានរៀនដល់ថ្នាក់ទីបីទីបួនដែល?

ខៈ ចាស! អ៊ុំចេះតែទៅទៅ។

កៈ ហាហ! អញ្ចឹងត់សូម្បីតែក ខ គ អីក៏អ៊ុំអត់ចេះដែល?

ខៈ ចេះចេះ( ក ខ គ ឃ ) អី។ ក ខ អីនឹងចេះហើយស្រៈ :អ ា អីនឹងចេះ។

កៈ ចាសអ៊ុំ!

ខៈ តែអត់ចេះបូកលេខ! ចេះតែប្រកប។

កៈ អាប្រកបដាក់ពេលសរសេរនឹងមែនអ៊ុំ?

ខៈ ចា! នឹងហើយ។ ប្រកបអត់ចេះ។

កៈ ចាសអ៊ុំ!

ខៈ អត់ចេះប្រកបសោះ!

កៈ ចាស! ប៉ុន្តែបើអត់ចេះនិយាយមួយទៀតបានពិបាកមែនទេអ៊ុំ?

ខៈ ចាសនឹងហើយ!

កៈ តែនេះអ៊ុំអត់ចេះតែអានហើយនឹងសរសេរ!

ខៈ ចាចា!

កៈ អញ្ចឹងតើអ៊ុំបានរៀននៅសាលាណាដែល?

ខៈ នោនឹងសាលាអូរដំបងពីរនេះឯង!

កៈ សាលាអូរដំបងពីរនេះ?

ខៈ ចាសនឹងហើយ! នៅអូរពីរយើងនេះ។

កៈ ចាស! អញ្ចឹងសាលារៀននឹងមានតាំងពី, ពីជំនាន់អ៊ុំមក?

ខៈ ចាស! មានតាំងពីជំនាន់ខ្ញុំមក។

កៈ អូចាសអ៊ុំ! ខ្ញុំរៀននៅសាលារៀននឹងដែលតើអ៊ុំ!

ខៈ ចាស! មានតាំងពីជមនាន់ខ្ញុំមកម្លះ។

កៈ ចាស! អញ្ចឹងផ្ទះដែលអ៊ុំនៅសព្វថ្ងៃនេះអ៊ុំនៅតាំងពីអ៊ុំមានគ្រួសារមក?

ខៈ ចាស! នោកនៅនឹងផ្ទះឯក្រោយនោក!

កៈ អូ! ចឹងនៅខាងករោយនោះវិញ?

ខៈ ចាស!ដល់ពែលដែលវាចេញចូលពិបាកពេកវាភ្លក់ជ្រាំពេក។

កៈ ចាសអ៊ុំ!

ខៈ ដូចថាយើងចង់ចាក់ដីចាក់អីគេមិនអោយយើងចូល។

កៈ ចាសអ៊ុំ!

ខៈ ដល់ពេលគេមិនអោយយើងចូល! ខ្ញុំខ្វិលខ្ញុំក៏ខ្ញុំមកនៅមកនៅខាងមុខនេះទៅ។

កៈ អូ! នេះជាដីរបស់អ៊ុំហី?

ខៈ ចាស!

កៈ អូ! ខ្ញុំស្មានតែដីនេះវាជារបស់រដ្ឋរបស់អីអញ្ចឹងហាស់! ដោយសារតែវានៅជិតមាត់អូរចឹងហ្ន!?

ខៈ ចាសចា! ដីរបស់យើងក៏ដូចជាដីរបស់រដ្ឋ!

កៈ ចាស!

ខៈ បើយើងសុំគេ!

កៈ អូមួយនេះអ៊ុំបានសុំរដ្ឋហើយនឹងមេឃុំគេនៅហី?

ខៈ ចាសចា!

កៈ អូខេអ៊ុំ!

ខ៖ អោយតែយើងនៅកើត!

ក៖ ចាស!

ខ៖ ដូចថាបើសិនជាមានឡានមកប៉ះនឹងផ្ទះរបស់យើងអី! យើងអត់មនាសិទ្ធិទៅរករឿងអោយគេទេអីគឺអត់បានទេ។

ក៖ អូ! ហ៊ឹម! ដោយសារតែយើងនៅមាត់ផ្លូវរបស់គេមែនទេអ៊ុំ?

ខ៖ ចាសចាស!

ក៖ អូខេយល់អ៊ុំ!

ខ៖ មើលដូចអ៊ុំផ្ទះហើយអ៊ុំចេកម៉ាចអីគាត់នៅនឹងមាត់ផ្លូវនឹងដែលទាំងអស់។

ក៖ ចាសអ៊ុំ! ចាខ្ញុំបានឃើញអ្នកដើរនៅម្តុំមាត់អូរខាងនោះ!

ខ៖ ចាសចាស!

ក៖ គេនៅខាងមាត់អូរចឹងដូចជាអ៊ុំដែល!

ខ៖ ចាស!

ក៖ ប៉ុន្តែតើអ៊ុំមានភ័យដែលទេ?

ខ៖ អត់ទេ!

ក៖ ពេលដែលមានភ្លៀងហើយទឹកលិចទឹកអីមក?

ខ៖ អត់ទេ!

ក៖ ហ៊ឹម!

ខ៖ បើទប់វាអស់ហើយ! មានទៃបាក់ពីខាងនោះមកវិញ?

ក៖ ចាស! អញ្ចឹងតើអ៊ុំបានរើរមកនៅដីនៅមាត់អូរនេះបានប៉ុន្មានឆ្នាំដែលហើយ?

ខ៖ ហ៊ឺ! បានប៉ុន្មានទេ? បានបួនឆ្នាំហើយ! ប្រាំឆ្នាំហើយ។

កៈ អូបានយូរដែលហើយ!

ខៈ ចាស!

កៈ ហើយផ្ទះរបស់អ៊ុំនៅខាងក្រោយនោះកូនចៅរបស់អ៊ុំពួកគាត់ជាអ្នកនៅហី?

ខៈ ចាស! អត់ទេ។

កៈ អញ្ចឹងបានរើរយកមកដាក់នៅនឹងមុខនេះអស់ហើយ?

ខៈ ចាស!បានរើរយកមកដាក់នៅនិងមុខនេះអស់ហើយ!

កៈ ចាស! អញ្ចឹងតើសព្វថ្ងៃនេះតើអ៊ុំរស់នៅតែពីរនាក់ប្ដីហើយនឹងប្រពន្ធតើហីអ៊ុំ? ឬមានកូនមានចៅអីដែលពួកគាត់រស់នៅជាមួយនឹងអ៊ុំដែល?

ខៈ នៅ! នៅមានកូនស្រីមួយហោ?

កៈ ចាស! នៅកូនស្រីអ៊ុំដែលគាត់អត់ទាន់រៀបការនឹងមែន?

ខៈ អត់ទេ! រៀបការរួចម្ដងហើយ។ តែដល់ពេលនេះទៅគេលេងគ្នា!

កៈអូ!  ចាស!

ខៈ នោះបានកូនមួយហោក!

កៈ អូអាអូនមួយតូចនោះហាស់?

ខៈ ចាស! នឹងហើយបានកូនមួយ។

កៈ ចាស! ឡើងគួរអោយស្រឡាញ់។ ចាស

ខៈ ចាស! បានមួយនៅជាមួយនឹងទៅ។

កៈ ចាស! អញ្ចឹងអ៊ុំបានទៅរៀនហើយបានរៀននៅសាលាអូរដំបងពីរយើងនេះ។ ហើយតើកាលដែលអ៊ុំទៅរៀននឹង! តើអ៊ុំមានបានលុយទៅរៀនអីទេអ៊ុំ?

ខៈ គ្មានបានអីទេ! អត់។

កៈ ហ៊ឹម!

ខ៖ ជូនណាទោ! ជូនណាទៅមានបាយ, ជូនណាទៅអត់បាយមួយដុំទៅ, ដើរទៅ!

ក៖ ចាស!

ខ៖ ជូនណាទៅក្ដារសរសេរគ្មានទេ! ហើយអារឈើនេះធ្វើក្ដារកំពៀកទៅហើយ។

ក៖ ចាសអ៊ុំ!

ខ៖ អាក្ដារយើងនឹងឈើយើងនឹង?

ក៖ ឈើចាស!

ខ៖ កំពៀកទៅហើយ។

ក៖ ចាស!

ខ៖ ចេះតែទៅហើយ។

ក៖ ចាស!

ខ៖ ហើយសំពត់រហែករហែកអីចេះតែទៅហើយ។

ក៖ ចាស! គ្មានទេចេះតែទៅហើយ! ពីដើមហ្វសំពត់មិនដូចឥឡូវនេះតែ!

ក៖ ចាស!

ខ៖ អូ! ពីដើមបានគេចោលសំពត់មួយអីអរណាស់! បានគេចោលមួយអីអរណាស់។

ក៖ ចាស!

ខ៖ ពីដើមណាស់គ្មានទេសំពត់ហាស់? ដេរកញ្ចែកកញ្ចុបអីចេះតែទៅហើយ, ចេះតែទៅរៀន ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ ដេរ! ហើយឥឡូវនេះគ្មានទេ! ទោះបីជារហែកបន្តិចបន្តួចអីគេមិនស្លៀកមិនពាក់ទេ!

ក៖ ចាស!

ខ៖ គេមិនពាក់ទេ។

ក៖ ចាស!ឥឡូវនេះដូចថា?

ខ៖ វាទាន់សម័យ។

ក៖ ចាស! ប្រទេសអភិវឌ្ឍន៍ទៅអភិវឌ្ឍន៍ចឹងហាស់អុំ?

ខ៖ ចាស!

ក៖ អញ្ចឹងលេងខ្លះខាតទៀតហើយខាងសំម្លៀកបំពាក់។

ខ៖ ចាស!

ក៖ និយាយទៅអ្នកខ្វះខាតនៅតែខ្វះខាត!

ខ៖ ចាស!

ក៖ តែគាត់អាចទិញសម្លៀកបំពាក់ពាក់បាន!

ខ៖ ចាស! អាចទិញសម្លៀកបំពាក់ពាក់បាន។

ក៖ ចាស! ទិញបានស្លៀកពាក់ត្រឹមត្រូវអត់ដូចកាលពីចំនាន់មុនទេ។

ខ៖ កាលពីជំនាន់មុខហាស់! យាយយាយគាត់មានក្បិនមួយគាត់ហែកជាពីរ, ហែកជាបីនាំគ្នាបិទបាំងរាងកាយ។

ក៖ ចាសសអុំ!

ខ៖ ទិញក្បិនមួយមកនាំគ្នាហែកធ្វើកំព្រោងស្លៀកទៅ។

ក៖ ចាសអុំ!

ខ៖ មានស្អីទេ!ស្ងួម្បីតែភួយក៏គ្មានដណ្តប់ដែល!

ក៖ ចាសអុំ!

ខ៖ ពីបុរាណបុរាណយើងមកហ្វ! ក្រណាស់

កះ ចាសអ៊ុំ!

ខះ សំពត់នឹងក៏គ្មានដែល!

កះ ចាសអ៊ុំ!

ខះ បើស្រូវអីធ្វើបានហូប!បើនិយាយពីរឿងលុយកាក់អីមិនសូវមានទេ។

កះ ចាស! អញ្ចឹងអ៊ុំធំឡើងតើអ៊ុំមានស្រែចំការធ្វើដែលទេ?

ខះ ខ្ញុំអត់មានទេខ្មោចយាយតាគាត់លក់អស់ហើយ!

កះ ចាសអ៊ុំ!

ខះ នោកប្អូនរបស់ខ្ញុំហោក!

កះ ចាស! អញ្ចឹងតើដអ៊ុំចេះធ្វើស្រែដែលទេ?

ខះ ខ្មោចឪពុកខ្ញុំជាអ្នកធ្វើតើ។

កះ ចាសចាស!

ខះ ប៉ុន្តែដល់ពេលដែលអស់ពីខ្មោចឪពុកទៅ, គេយកស្រែយកចំការអស់រលីង! ឥឡូវនេះគ្មានស្អីទេ។

កះ ចាស!

ខះ គេយកអស់ស្រែយើងចាំការយើង!

កះ ចាស! អញ្ចឹងនៅក្នុងគ្រុមគ្រួសាររបស់អ៊ុំគឺជាអ្នករកស៊ីលក់មែនទេ?

ខះ ចាស!

កះ ចាស! ហើយអ៊ុំក៏ជាអ្នករកស៊ីលក់ដែល? លក់នំលក់អី!

ខះ អញ្ចឹងតើអ៊ុំបានឆប់លក៏នំលក់ដូរហាស់?

ខះ ចាស!

កៈ ពីអាយុប៉ុន្មានដែល?

ខៈ អូ! ពេលដែលអ៊ុំចាស់ហើយ! ទឹមតែកូនគេមានគ្រួសារអស់ហើយហើយគេបែកបាក់គ្នាអស់ហើយបានឈប់។

កៈ ចាស! ហើយការលក់របស់អ៊ុំនឹង, គឺរ៉ែកដើរលក់រហូតមែនទេ?

ខៈ ចាស! រ៉ែកសង្រែកនោះនោកសង្រែកនោះ។

កៈ ចាស! អញ្ចឹងតើមាន?

ខៈ នោះសង្រែកនោះមិនទាន់ចោលផង។

កៈ ចាស!ខ្ញុំឃើញហើយអ៊ុំ!

ខៈ ចាស!

កៈ ចាស! ខ្ញុំដូចជាធ្លាប់បានឃើញអ៊ុំដើររ៉ែកអីលក់?

ខៈ ចាស! រ៉ែកនំលក់ទៅរ៉េកសាច់ជ្រូកទៅ, មួយគីឡូពីរគីឡូអីទៅត្រឹមួយគីឡូពីរគីឡូអីចេះតែដើរលក់ទៅ។

កៈ ចាសអ៊ុំ!

ខៈ ហើយមាននំខ្លះដាក់ពីលើវាមក! ស្អុបដាក់ពីលើវាទៅ។

កៈ ចាសអ៊ុំ!

ខៈ ជូនណាទៅកាលណឹង! កាលម្តាយរបស់ខ្ញុំគាំនៅរស់ខ្ញុំអោយម្តាយេរបស់ខ្ញុំគាត់លក់នៅនឹងផ្ទះហើយខ្ញុំដើររ៉ែកលក់ទៅ។ រ៉េកដើរទៅលក់ទៅហើយបានលុយបានកាក់មកវិញរៀបរ៉ាប់លុយអោយម្តាយទៅ។ ហើយព្រលឹមឡើងទៅទៀតទៅ។

កៈ ចាសអ៊ុំ!

ខៈ ចាស! គ្មានអីជិះទេ។

កៈ ចាស!

ខះកាលនឹងនោះ។

កៈ ចាស!សូម្បីតែកង់មួយក៏អត់មានដែលអ៊ុំ?

ខះ បើកង់មិនចេះជិះផង!

កៈ អូ!

ខះ អត់ចេះ! រៀន, រៀនឡើងឈើខ្លួន។

កៈ ដូលមែនអ៊ុំ?

ខះ ចាសរៀនអត់ចេះ!

កៈ អញ្ចឹងពិបាកហើយអ៊ុំ!

ខះ ចាស!បានទៃដើរនៅនឹងដី។

កៈ ចាស! អញ្ចឹងតើតាមតែខ្ញុំស្តាប់អ៊ុំមើលទៅ! អ៊ុំលក់នំលក់អីបាននឹងគឺអ៊ុំចិញ្ចឹមគ្រុមគញ្ញរួសារ របស់ទាំងមូលមែនអត់អ៊ុំ?

ខះ ចាស! ទាំងមូលនឹងឯង។

កៈ ចុះតើប្តីរបស់អ៊ុំតើគាត់មនរកស៊ីជួយអ៊ុំអីដែលអត់ទេ?

ខះ មានជួយស្អីខ្ញុំទេកលានឹងហូ! គែដើរលេងសប្បាយ។ ស៊ីចាយពួកម៉ាកគ្នាគេ។

កៈ ចាស។

ខះ ពួកម៉ាកពួកភឿនតិចគ្នាគេ!

កៈ ចាស!

ខះ ខ្ញុំ! ខ្ញុំគ្មានស្អី! បើខ្ញុំមិនរកតើមែានស្អីអោយកូនហូប?

កៈ ចាសអ៊ុំ!

ខះ មានជួយស្អី!?

ក៖ ចាស! អញ្ចឹងអ៊ុំរកតែឯង?

ខ៖ ចាស!

ក៖ អូ! ខ្ញុំសូមសសើរអ៊ុំហើយដោយសារតែអ៊ុំរកស៊ីតែម្នាក់ឯងហើយលក់ដូរប៉ុននឹងតែអ៊ុំចិញ្ចឹម មួយគ្រួសារអ៊ុំរស់ហាស់។ ចិញ្ចឹមតាំងគ្រួសារទាំងមូលទៀត។

ខ៖ ចាស! ខ្ញុំហាស់តាំងពីកូនកើតមកបានមួយខែកន្លះ! ខ្ញុំទៅធ្វើការអោយគេ, ខ្ញុំធ្វើការអោយ គេទាំងមេឃភ្លៀងហូរពីលើមកហោក។

ក៖ ចាសអ៊ុំ!

ខ៖ ហើយខ្ញុំអត់ចេះទាស់អត់ចេះអី!

ក៖ ចាសអ៊ុំ!

ខ៖ ដល់ពេលចាសើខ្លួនតើបានចេះឈើប៉ុនដោយ។

ក៖ ចាសអ៊ុំ!

ខ៖ បានចេះឈើ! ចង់ងាប់ចង់រស់ហូ!

ក៖ ចាស! មួយនឹងក៏ជាសំណាងដូចថារបស់អ៊ុំដែល។

ខ៖ ចាស!

ក៖ ហើយបើសិនជាអ៊ុំឈើទៀតកាលនឹងប្រហែលជាគ្រួសាររបស់អ៊ុំនឹងត្រូវយ៉ាប់។

ខ៖ ហ៊ឹម! កូនងាប់បាត់អស់ហើយ។

ក៖ ចាស់!

ខ៖ ចាស! ហើយប្រហែលជាគ្មាននរណាមើលនរណាទេ!

ក៖ ចាសអ៊ុំ!ប៉ុន្តែអ៊ុំបានធូរហើយ ដោយសារតែឥឡូវនេះកូនរបស់អ៊ុំពួកគាត់មានគ្រួសារអស់ ហើយនៅតែកូនស្រីរបស់អ៊ុំមួយទៀត។

ខ៖ ចាសចាស!

កៈ នឹង! អញ្ចឹងខ្ញុំអត់ដឹងថាខ្ញុំបានសួរអ៊ុំនៅសំនួរនេះរនៅទេ!

ខៈ ចាស!

កៈ ប៉ុន្តែកព្រៅពីការងារលក់ដូរនំនឹងតើអ៊ុំមានបានធ្វើការងារអ្វីផ្សេងពីនឹងទៀតដែលអត់ក្រៅពីការដើររ៉ែកលក់នំទេអ៊ុំ?

ខៈ អ៊ុំដើរចាក់ដីវាត់ដីចមនុស្សប្រុសអញ្ចឹង!

កៈ អូ! តើអ៊ុំដើរចាក់ដីហី?

ខៈ ចាស! ចាក់ដីរ៉ែកដី! ចាក់(ជីកដី)រ៉ែកដីឡើងពីអូរ, ជូនណាទៅប្រឡាយវត្តហើយកន្លែងប្រឡាយយើងទៅចេះនេះហ្វ?

កៈ ចាសអ៊ុំ!

ខៈ ចាស! ខ្ញុំនេះហើយដែលលើហ្វ! ហើយកន្លែងប្រឡាយមុខផ្ទះអ៊ុំគុលអីហ្វ?

កៈ អូចា!

ខៈ ខ្ញុំនេះហាលយលើធ្វើថ្នល់អីហ្វ?

កៈ អូនៅផ្ទះរបស់ខ្ញុំអីនឹងមែនអ៊ុំ?

ខៈ ចាស!

កៈ អូ! តើអ៊ុំជាអ្នកជីក?

ខៈ អាកន្លែងនឹងហើយចេះតែចាក់ចេះតែទប់ទាំងអស់គ្នាហ្វ!

កៈ អូចាស!

ខៈ ចាក់ក្រវាត់ដូចមនុស្សប្រុសអញ្ចឹង។

កៈ ចាសកាលនឹងខ្ញុំចាំម៉ាក់របស់ខ្ញុំគាត់ជួយហាស់?

ខៈ ចាស!

កៈ គាត់ជួយអោយគេចាក់ដីលើកហោ?

ខ៖ ចាស!

ក៖ ប៉ុន្តែខ្ញុំអត់ដឹងថាគាត់ជួយអ្នកណា។ អត់ដឹងថាជាអ៊ុំ!

ខ៖ ចាស! នៅមុខផ្ទះអ៊ុំតុលអីនេះសុទ្ធតែខ្ញុំជាអ្នកលើកហើយ។

ក៖ ចសអ៊ុំ!

ខ៖ ទៅមនុស្សប្រុសមនុស្សស្រីអីចេះតែលើកហើយ។

ក៖ចាស១

ខ៖ ទៅមួយម៉ែត ២០០០រៀលទៅ៣០០០រៀលចាក់វ៉ាត់ចេះតែទៅទៅ។

ក៖ វាយ! ខ្ញុំសូមសសើរអ៊ុំមែនទែននៅកំម្លាំងរបស់ហាស់! ដោយសារតែអ៊ុំជាមនុស្សស្រីតែអ៊ុំមានកម្លាំងធ្វើការដែលធ្ងន់ៗបាន។

ខ៖ នៅនេះគ្មានអ្នកណាទេល្បីហ្ន! មានតែខ្ញុំទេដែលលបីជាងគេហ្ន។

ក៖ ចាស!

ខ៖ គ្មានមនុស្សស្រីឯណាទៅលើកដីហើយធ្វើការអញ្ចឹងៗទេ! គ្មានទេ

ក៖ ចាសអ៊ុំ! ចុះអ៊ុំប្រុសមានជួយអ៊ុំដលកាលនឹង?

ខ៖ ជួនណាគេក៏ជួយទៅហើយជួនណាក៏អត់ទទៅ! ហើយជួនណា: គេដើរបាត់ទៅ! ហើយគាត់ទៅធ្វើការជាងឈើឯនោកដល់ពេលគេធ្វើការហើយទៅគេបើកលុយហើយគៃដើរស៊ីចាយបាត់ទៅ។

ក៖ ហ៊ឹម!

ខ៖ គ្មានស្អីទេ! គៃដើរលេងបាត់ទៅ។

ក៖ ចាសអ៊ុំ។ អញ្ចឹងជីវិតរបស់អ៊ុំសព្វថ្ងៃនេះខុសគ្នាពីជីវិតរបស់អ៊ុំនៅពីក្មេងយ៉ាងម៉េចខ្លះដែល?

ខ៖ ចាស! វានៅតែពិបាកអញ្ចឹង! វានៅតែដើប៉ះស្លឹកឈើស្លឹកព្រៃលក់! ហើយបើសិនជាយើងមនរកវាអត់។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ តែឥឡូវអ៊ុំដូចថាពីមុនតើអ៊ុំមានខ្វះខាងអាហារហូបចុកទៀតដែលអត់?

ខ៖ ខ្វះទាំងអស់នឹង! ខ្វះរហូត។

ក៖ ចុះឥឡូវនេះវិញ?

ខ៖ ឥឡូវនេះក៏ខ្វះដែល! គ្រាន់ថាបានគេប៉ុលអង្ករអញ្ចឹងទៅមួយអាទិត្យគេយកម្ដងមួយអាទិត្យគេយកមួយដងចឹងហាស់។

ក៖ ចាស!

ខ៖ នឹងហើយបានគេប៉ុលអង្ករអោយចឹងទៅ! ហើយជូនណាទៅបានព្រះវិហារអោយមួយការ៉ុងទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ចាស! បានហូបទៅ។

ក៖ ចាសនឹងហើយអ៊ុំ! អញ្ចឹងដូចថាជីវិតរបស់អ៊ុំកើតទាន់សម័យប៉ុលពតតើមែនទេ?

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំកើតទាន់ជំនាន់នឹងតើអ៊ុំបានឆ្លងកាត់បញ្ហាហើយនឹងបទពិសោធលំបាកអ្វីខ្លះដែលអ៊ុំបានឆ្លងកាត់កាលពីជំនាន់នឹង?

ខ៖ ហ៊ឺ ឆ្លងកាតអស់ហើយ!

ក៖ តើអ៊ុំអាចនិយាយប្រាប់ខ្ញុំដូចជាអោយបានលំអិតតិចពីរឿងនឹងតើបានទេអ៊ុំ?

ខ៖ កាលនឹងខ្ញុំ! មិនទាន់បានជានារីពេញសិទ្ធទេ។

ក៖ ចាសអ៊ុំ!

ខ៖ គេនារីពេញសិទ្ធគេដើរធ្វើតែដើរដកស្ទូងតែដើរតាមលើកដីលើកអីតាមនេះគេ! ខ្ញុំនីសាលារៀន! ហើយខ្ញុំនៅសាលារៀននឹងខ្ញុំមិនចេះអីទេ។

ក៖ ចាសអុំ!

ខ៖ ដល់តែពេលចូលដល់ឆ្នាំ៧៧គេដេញ់អោយខ្ញុំអោយទៅនៅទៅនោះ! ហើយដេញ់អ្នកនោះមកនេះវិញ។

ក៖ ចាសអុំ!

ខ៖ ហើយខ្ញុំកាលនឹងគ្មានបានទៅនៅជាមួយម្តាយអីទេ។

ក៖ ចាសអុំ!

ខ៖ ជីដូនខ្ញុំគាត់យកខ្ញុំទៅ។

ក៖ ចាស!

ខ៖ ដល់ពេលយកខ្ញុំទៅ! ម្តាយនឹកកូនពេកទៅម្តាយអត់អោយមកវិញទៀត។

ក៖ ចាសអុំ!

ខ៖ នៅនឹង, មានស្អីហូប! អ្នកធ្វើការបានមួយស្លាបព្រាបបរ។

ក៖ ចាសអុំ!

ខ៖ មួយស្លាបព្រានឹងទឹកកូឃ្លោកបានស្អី!

ក៖ ចាសអុំ!

ខ៖ ហើយបើអ្នកធ្វើការមិនបានហូបស្អីអត់ចុះ! គ្មានស្អីទេ! ជូនណាំទៅដើរប៉ះស្លឹកឈើស្លឹកព្រៃអីទៅគ្មានប្រុកទេ។

ក៖ ចាសអុំ!

ខ៖ ហើយភ្លើងគេមិនអោយយើងឃើញទេ, គេមិនអោយយើងបង្កាត់ទេ។

ក៖ ចាស!

ខ៖ គេទុកអោយយើងអត់ស្លាប់។ ហើយយើងចេះតែលួចទៅចេះតែអីទៅ! ហើយចេះតែដើរទៅបូតអាស្រូវនៅក្នុងទឹកលិចហ្ន!

ក៖ ចាសអ៊ុំ!

ខ៖ ហើយដើរបូតទៅនៅក្នុតទឹកនឹងទៅហើយយកមកបូតហើយស្ងួរបុកលីងហូបទៅ។

ក៖ ចាសអ៊ុំ!

ខ៖ បុកលីងហូបទៅ! វេទនាណាស់។ គ្មានថ្ងៃណាហើយពេលណាដែលសប្បាយទេ, ហើយគ្មានពេលណាដែលទំនេរទេ។

ក៖ ចាស!

ខ៖ បើយើងមិនរក! ជួនណាទៅ, អាដំដូងគេវាលិចទឹកហ្ន?

ក៖ ចាសអ៊ុំ!

ខ៖ ជ្រមុជទឹកទៅកាយ! កាយមកដូចដំឡូងគ្រាប់ខ្មោរចឹងអាគ្រប់ខ្មោរតូចៗហ្ន?

ក៖ ចាសអ៊ុំ!

ខ៖ យកវាមកស្ងួរទៅហើយចែកគ្នាហូបទៅ។

ក៖ ចាស!

ខ៖ ហើយបើឃើញយើងមានភ្លើងអីគេចាប់យើងហើយ!

ក៖ ហ៊ឹម!

ខ៖ ហើយវាចេះតែលួចលាក់ទៅ, ចេះតេបិទបាំងវាទៅកុំអោយវាហុយផ្សែង។

ក៖ ចាសអ៊ុំ!

ខ៖ កុំដោយហុយ។

ក៖ ចាស! នឹងអ្នកដែលមានជីវិតរស់មកដល់សព្វថ្ងៃនេះដូចថាជីវិតរបស់ពួកគាត់ពិតជាសំណាងមែន។

ខ៖ ចាសចាស! សំណាងហើយ,បើ អ្នកខ្លះងាប់មួយសំបុបកយកទៅទាំងអស់។

ក៖ ចាសអ៊ុំ!

ខ៖ យកទៅទាំងអស់!

ក៖ ទាំងគ្រួសារប៉ុនដោយ?

ខ៖ ចាស! អត់មានទុកទេ, អោយតែខូចមួយយកទៅទាំងអស់ហើយ។

ក៖ ចាសអ៊ុំ!

ខ៖ ដាក់ចងខ្សែច្រវ៉ាក់នឹងអូសទៅហើយ។

ក៖ ចាសអ៊ុំ!

ខ៖ វ៉ាវវ៉ាវ!

ក៖ ចាស! អញ្ចឹងតើគ្រួសាររបស់អ៊ុំហាស់?

ខ៖ ចាស!

ក៖ តើមាននរណាម្នាក់ដែលបានស្លាប់ដែលត្រូវបានសម្លាប់ដោយសារប៉ុលពតដែលឬអត់?

ខ៖ ចាស! ឪពុកខ្ញុំនេះហើយដែលគេសម្លាប់ហ្ន!

ក៖ ចាសអ៊ុំ! អញ្ចឹងមានតែឪពុករបស់តែម្នាក់តើហី?

ខ៖ ចាស!

ក៖ ហ៊ឹម!

ខ៖ ចាស! ឪពុកខ្ញុំនឹងឯង។

ក៖ ចាស!

ខ៖ ហើយឪពុកមាមួយដែល!

ក៖ ពីរនាក់?គេយកគាត់ទៅសម្លាប់ដែល?

ខ៖ ចាស! គេយកទៅសម្លាប់ដែល!

ក៖ ចាស! ស្តាយពូកគាត់មែនទែនអ៊ុំ។

ខ៖ ចាស!ដល់ពេលអញ្ចញចឹង! បើកុំអញ្ចឹង! ហូឪពុកខ្ញុំគាត់នៅសំបូរសប្បាយណាស់។ គាត់កាលនឹងគាត់និយាយកូនអើយ! ឆ្នាំនេះស្រូវហាស់, ល្អណាស់! ឪពុកនៅវិញណាស់កូនអើយនឹងសប្បាយហើយ។ គាត់ពោលគាត់ធូរចឹងណាស់។ មិនដឹងថាបើឪពុកនៅសប្បាយ! តេបើអស់ពីពុកទៅគ្មានទេកូន។ មែនគ្មានមែន!

ក៖ ចាសអ៊ុំ!

ខ៖ អញ្ចញចឹងមែន! តាមមាត់របស់គាត់។

ក៖ ចាសអ៊ុំ!

ខ៖ ឪពុករបស់ខ្ញុំគាត់ស្លូតណាស់! ហើយឪពុករបស់ខ្ញុំគាត់មិនដែលធ្វើអីផងនេក។ គាត់ដើរលើកដីនៅតាមមាត់តអិរនេក!

ក៖ចាស!

ខ៖ លើកអូរតាមមាត់នេកឡើងជំរៅបីម៉្រែតបូនម៉្រែតហូនេក! អាកន្លែងដែលមានដើមគោហោក។

ក៖ ចាសអ៊ុំ!

ខ៖ កន្លែងដើមគោនឹងគាត់លើកដីឡើងមក!ហើយគាត់ដីនឹងដាក់ជញ្ជៀងហាស់!

ក៖ ចាសអ៊ុំ!

ខ៖ គ្មានភ្លើងអីទេអុជជញ្ជៀងហាស់!

ក៖ ចាសអ៊ុំ!

ខ៖ គ្មានភ្លើងអីទេអុជជញ្ជៀងហើយកើមៗឡើងមក! អុជជញ្ជៀងលើកដី។

ក៖ ចាសអ៊ុំ! ចឹងគាត់ធ្វើការទាំងយប់ន៍អ៊ុំ!?

ខ៖ ចាស! គាត់ធ្វើការទាំងយបទាំងថ្ងៃហាស់!?

កៈ ហ៊ឹម!

ខៈ ឪពុករបស់ខ្ញុំហ្នគាត់នឿយណាស់! ហើយបានមកដល់គីនទៀត! អ៊ុំមីនេះក៏អញ្ចឹងហើយខ្ញុំនេះក៏អញ្ចឹង។

កៈ ចាស!

ខៈ បានឆ្លងកាត់ដូចគ្នា។

កៈ ចាស! អញញចឹងតើទាន់សម៧យប៉ុលពតនឹងតើអ៊ុំស្រីកើតទាន់នឹងអ៊ុំមានអាយុប៉ុន្មានឆ្នាំដែល?

ខៈ បើគិតទៅអាយុជាងដប់ឆ្នាំហើយ!

កៈ អូ! ជុំដឹងក្តីហើយ!

ខៈ ចាជាង១០ឆ្នាំ!

កៈ ចាស! កាលនឹងតើគេប្រើអ៊ុំអោយធ្វើការអ្វីដែល?

ខៈ ហ៊ឺ! គេប្រើអោយបោកស្មៅ។

កៈ អោយបោកស្មៅ?

ខៈ ចាស! ហើយបើយើងមិនទៅបើយើងមិនទៅអត់។

កៈ ចាស!

ខៈ ហើយចេះតែទៅទៅ។

កៈ ចាស! នឹង, អញ្ចឹងពេលដែលរួចប៉ុលពតហើយហាស់អ៊ុំ!? អញ្ចឹងតើអ៊ុំបានជួបជុំគ្រួសាររបស់អ៊ុំអីធម្មតាទេន៍អ៊ុំ?

ខៈ ចាធម្មតា!

កៈ ចាស! ហឺ?

ខ៖ រត់! យួនវាដេញបាញ់! រត់ហែងតាំងពីអូរខ្លាយមកពីអូរខ្លាយមកដល់អូរសាឡៀហើយពីអអូរសាឡៀមកមកដល់ផ្ទះប៉ុនដោយ។ មកដល់ស្រុកប៉ុនដោយ។

ក៖ ចាស! មកដល់បាត់ដំបងនេះ?

ខ៖ ចាស!មកដល់ស្រុក។

ក៖ ចាស! ហ៊ឹមហើយអញ្ចឹងក៏នៅទីនេះរហូតតាំងពីពេលនឹងមកទៅ?

ខ៖ ចាស !តាំងពីបរមបររានមក។

ក៖ ចាស!ហើយបានជួបជុំគក្រុមគ្រួសារទាំងអស់គ្នា?

ខ៖ ចាស!

ក៖ ហើយសប្បសយរីករាយទៅ?

ខ៖ ចាស!

ក៖ អញញចឹងក្នុងគ្រួសាររបស់អ៊ុំតើមានាអ្នកណាចេះខាថផ្នែកតន្ត្រីឬក៏ខាងផ្នែកសាងសង់ឬក៏តើពួកគាត់មានចេះជំនាញអ្វីមួយទេដែលថាជាទេព្យកោសល្យរបស់ពួកគាត់ហាស់អ៊ុំ?

ខ៖ ចាសអត់!

ក៖ អត់មានទេន៏អ៊ុំ!? ហើយមានតែម្តាយរបស់អ៊ុំទេដែលគាត់ចេះធ្វើនំលក់?

ខ៖ចាស!

ក៖ ចាស! គាត់មានជំនាញខាងធ្វើនំខ្មែរចាសហើយនឹងអ៊ុំផងដែល។

ខ៖ ចាស!

ក៖ អញ្ចឹងអ៊ុំផ្ទះរបស់អ៊ុំ! ពេលដែលរួចពីសង្គ្រាមនឹងនឹងហើយតើគ្រួសាសររបស់អ៊ុំស្រីយ៉ាងម៉េចដែលនិយាយពីជីវភាពហាស់!?

ខ៖ កាលនឹងផ្ទះរបស់ខ្ញុំគេវេរិសអស់ហើយ!

ក៖ ចាស!

ខ៖ គែរេរើរអស់ហើយ! ក៏នាំគ្នាទៅរើរពីផ្ទះនៅឯត្រើយមួយខាងមកហើយនាំគ្នាំសែងនាំគ្នាលីមកយកមកធ្វើនៅ! ហើយធ្វើនៅទៅ។

ក៖ ចាសអ៊ុំ!ចាស!

ខ៖ ចាស!

ក៖ ចាស! ហើយតើជីវភាំពគ្រួសាររបស់អ៊ុំសមរម្យទេ? ហើយតើមានអ្វីញាំគ្រប់គ្រាន់ដែលទេ?

ខ៖ មិនមានទេ។

ក៖ ហ៊ឹម!

ខ៖ កាលនឹងពួកយើងមិនមានគោមិនមានក្របីអីនឹងគេ! កាប់ជីកនឹងចបកបនឹង។

ក៖ ចាសអ៊ុំ!

ខ៖ កាប់នឹងបចបកាប់នឹងឡើងគេ, នេះទៅកេគ្រុមគេធ្វើស្រែគែចែកគ្នាមួយម្នាក់មួយតៅម្នាក់មួយតៅទៅ។

ក៖ចាសអ៊ុំ!

ខ៖ ដូចថាអ្នកណាធ្វើបានប៉ុន្មានតៅអីចឹងគេចែកតាមនឹងមក។

ក៖ ចាស!

ខ៖ ហើយអ្នកណាធ្វើបានបានប៉ុន្មានថ្ងៃគេចែកប៉ុននឹងមក

ក៖ ចាសអ៊ុំ!

ខ៖ ហើយបើអ្នកធ្វើបានពីឬថ្ងៃគេចែកតាំមពីរថ្ងៃនឹងមក!

ក៖ ចាសអ៊ុំ!

ខ៖នឹងធ្វើកាប់ចបកាប់ហាស់នឹងហាស់?

ក៖ ចាសអ៊ុំ!

ខ៖ កាប់ចបកាប់ទៅនាំគ្នាព្រោះទៅហើយច្រូតទៅនាំគ្នាយកមកបែនយកមកបោក។

កៈ ចាសអ៊ុំ!

ខៈ ហើយគ្មានគោគ្មានអីយកមកប៉ែនទេមនតែបោក។

កៈ ចាសអ៊ុំ! ហ៊ឹម

ខៈ វាវេទនាណាស់! បោកទៅនាំគ្នាប្រមូលផលទៅហើយបែកគ្នាទៅ។

កៈ ចាខសអ៊ុំ!

ខៈ វាមានតែប៉ុននឹងឯង។

កៈ ចាស! អញ្ចឹងតើអ៊ុំអចប្រាប់ខ្ញុំពីពេលវេលាដែលអ៊ុំគិតថាដែលវាពិបាកជាងគេនៅក្នុងជីវិតរបស់អ៊ុំហាស់! ដោយសារតែជីវិតរបស់អ៊ុំពិបាកហើយ! តាមអ្វីដែលខ្ញុំបានស្តាប់អ៊ុំមកហាស់?

ខៈ ចាស!

កៈ ចឹងតើអ៊ុំមានពេលវាលាណាដែលអ៊ុំគិតថាពិបាកជាងគេបំផុតហាស់ដែលអ៊ុំគិតថាពិបាកដើម្បីឆ្លងកាត់វាហាស់? តើអ៊ុំអាចរើសយកមកមួយឬក៏ពីរយកមកនិយាយបានទេ?

ខៈ ចាស! សព្វថ្ងៃនេះមិនពិបាកស្អីទេ

កៈ ចាសអ៊ុំ!

ខៈ ពិបាកនឹងប្តី! ពិបាកគិតមិនចេញ។

កៈ ហ៊ឹម! អញ្ចឹងតើអ៊ុំមានវិណាឬក៏មានដំណោះស្រាយណាដែឡទេសម្រាប់មួយនឹង?

ខៈ ដោះវាមិនចេញ!

កៈ ចាស!

ខៈគិតវាមិនចេញ!

កៈ តែខ្ញុំគិតថានៅពេលដែលគាត់បានស្តល់ដំណឹងល្អហើយពេលដែលគាត់បានទទួលបុណ្យជ្រមុជតឹកហើយខ្ញុំជឿថាគត់នឹងអាចផ្លាស់ប្តូរបាន។

ខៈ មិនដឹងដែល! ខ្ញុំថាអត់ចេញ។

កះ តើអ៊ុំជឿថា? អ៊ុំមានសចក្តីជំនឿទៅលើព្រះតើមានទេ?

ខះ ជឿ!

កះ ចាស! តើអ៊ុំគិតថាព្រះអាចក្រែប្រែគាត់បានដែលទេ?

ខះ បាន។

កះ ចាសហើ! អញ្ចឹងតើមួយនឹងពិបាកជាងគេមែនទេអ៊ុំ?

ខះ ចាស!

កះ អញ្ញចឹងតើអ៊ុំមានពេលវាលាណាដែលអ៊ុំសប្បាយរីករាយនៅក្នុងជីវិតរបស់អ៊ុំទេ? តើអ៊ុំគ្រានឹងដែលទេ?

ខះ អោយតែប្តីខ្ញុំគាត់អោយខ្ញុំសប្បាយចិត្តខ្ញុំនឹងសប្បាយ! ហើយបើប្តីមិនអោយសប្បាយគឺអត់សប្បាយប៉ុន្មានទេ។

កះ ហ៊ុម! ចាស! នឹងជីវិតរបស់អ៊ុំតាំឆ្លងកាត់មកនិយាយទៅតាំងពីតូចមកដល់ធំពិបាករហូត។

ខះ ចាស! ពិបាករហូត។

កះ ចាស!ហើយរហូតមកដលឥឡូវនេះទៀត។

ខះ ចាស!

កះ អញ្ចឹងតើអ៊ុំគិតថាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបានធ្វើអោយអ៊ុំស្រីសប្បាយចិត្តដែលទេ?

ខះ ចាសសប្បាយ។

កះ ចាសអ៊ុំ!

ខះ បាន ទៅព្រះវិហារសប្បាយ!

កះ ចាស!

ខះ ខ្ញុំមានអារម្មណ៍ថាសប្បាយហើយមានអារម្មណ៍ថាជ្រះថ្លា!

ក៖ ចាសចាស! ហើយតើអ៊ុំអាចប្រាប់ខ្ញុំបានទេថា! តើអ៊ុំស្រីបានស្គាល់ដំណឹងល្អតាមរយៈអ្នកណាគេដែលអ៊ុំ?

ខ៖ កាលនឹងតាមរយៈតាគោជងអីផង! ហើយដល់ពេលចុងក្រោយគេនោះបានកាម៉ា។

ក៖ ចាសអ៊ុំ!

ខ៖ ហើយកាម៉ាថា! បងអើយបងឯងចូលទៅ! អីទៅ, បងឯងចូលទៅព្រះជួយ។ អោយបងឯងធ្វើអ្វីអោយបានចង់ធ្វើអីចង់រកស៊ីអ្វីទៅវាបានអញ្ចឹងហាស់។

ក៖ ចាសអ៊ុំ!

ខ៖ ហើយខ្ញុំខិលហាស់ចូលទៅ។ យើងទៅណាអីយើងចូលប្រះហើយយើងរំលឹកទៅយើងអធិដ្ឋានទៅក៏ធូរទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!ហើយអត់មានភ្ញាក់ផ្អើលអីទេ! អត់មានភ័យខ្លាចអីទេ។ ហើយខ្ញុំចង់ដើរប៉ះស្លឹកឈើស្លឹកព្រៃអីក៏ដោយខ្ញុំអធិដ្ឋានទៅហើយវាគ្មានស្អីទេ។ អត់មានខ្លាចអត់មានប៉ះពាល់អត់មានស្អីទេ។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!ហើយបើខ្ញុំចង់សើរចឹង! ទៅព្រៃទៅដើរប៉ះស្លឹកឈើនៅក្នុងព្រៃអីចឹងទៅអ្នកខ្លះគេថាគេឃើញអានេះអានោះអីចឹងហាស់?

ក៖ចាសអ៊ុំ!

ខ៖ តែខ្ញុំមិនដែលបានឃើញទេ។

ក៖ ចាស!

ខ៖ ពីមុនខ្ញុំចេញខ្ញុំអធិដ្ឋានទៅ។

ក៖ ចាសអ៊ុំ!

ខ៖ បើអោយខ្ញុំភ្ញាក់ផ្អើលអីខ្ញុំរំលឹកទៅ។

កៈ ចាសអ៊ុំ!

ខៈ ចាស! ប៉ុននឹងឯង។

កៈ ចាសដោយសារតែការអធដ្ឋានរបស់អ៊ុំដល់ព្រះ?

ខៈ ចាសនឹងហើយ!

កៈ អធិដ្ឋានទៅដល់ព្រះទៅអោយព្រះជួយទៅ។

កៈ ជាសអ៊ុំ!

ខៈ អតមានភ័យអីភិតអីឬក៏ផ្អើលអីទេ។?

កៈ ចាសអ៊ុំ។

ខៈ អត់មានទេ!

កៈ ចាសអ៊ុំល្អមែនទែនវាជាបទពិសោធមួយល្អមែនទែន។

ខៈ ចាស!

កៈ អញ្ចឹងឥឡូវនេះជីវិតរបស់អ៊ុំដូចថាអត់ទាន់បានទទួលនៅសចក្តីសុកហាស់?

ខៈ ចាស!

កៈ បើយើងនិយាយទៅទរាង្គកាយរបស់យើងធ្លាប់ទេហាត់នឿយរហូតមក។

ខៈ ចាហាត់នឿយរហូត។

កៈ ចាអញ្ចឹងអ៊ុំអញ្ចឹងនៅថ្ងៃខាងមុខទៀតរបស់អ៊ុំតើអ៊ុំរំពឹងគិតចង់បានជីវិតបែបណាដែល?

ខៈ អ៊ុំចង់បានល្អ!

កៈ ចាស!

ខៈ សម្រាប់ផ្លូវទៅមុខ។

កៈ ចាស! អញ្ចឹងដូចជាតើអ៊ុំស្រីចង់មានបានស្អីគេខ្លះ?

ខ៖ និយាយទៅគិតវាមិនទាន់ចេញ។

ក៖ ចាស!

ខ៖ ជីវិតវាអត់ទាន់ពេញ! ខ្ញុំពិបាកត្រង់តែថាខ្ញុំអត់ចេះអានអក្សរនឹងឯងអញ្ចឹងហាស់។

ក៖ ចាសអ៊ុំ!

ខ៖ ខើញគេអានមកចង់ណាស់។

ក៖ ជាសអ៊ុំ!

ខ៖ ចង់អានអក្សរហើយចង់ដឹងរ៉ាក់ជ្រៅណាស់។

ក៖ ចាសអ៊ុំ!

ខ៖ នឹងចង់ដឹង, ចងដឹងពីគេមកអោយយើងវាម៉េចអីម៉េចហាស់?

ក៖ ចាសអ៊ុំ!

ខ៖ ចង់ដឹងហើយចង់ឮ! ហើយចង់ឃើញ។

ក៖ ចាស!

ខ៖ ចាអានអ៊ុំអត់ចេះចឹងហាស់បានជាអ៊ុំតូចចិត្តនឹងខ្លួនខ្ញុំនឹងហាស់។

ក៖ចាសអ៊ុំ! ហ៊ីមអញ្ចឹងពិបាកដែលបើអ៊ុំអត់ចេះអញ្ចឹង, ចឹងអ៊ុំអានព្រះគម្ពីរក៏អត់កើតដែលន៎អ៊ុំ?

ខ៖ ចាស!

ក៖ អញ្ចឹងតើអ្នកផ្សព្វផ្សាយសាសនាគាត់បង្រៀនអ៊ុំយ៉ាងម៉េចដែល?

ខ៖ គាត់គ្រាន់ទៃអោយខ្ញុំអធិដ្ឋានទៅហើយអោយខ្ញុំមើលេវីដែអូទៅ។

ក៖ ចាសមើលេវីដេអូហើយស្ដាប់ពួកគាត់អានអោយស្ដាប់ទៅមែនទេអ៊ុំ?

ខ៖ ចាស! ស្ដាប់ទៅ។

ក៖ ចាសល្អមែនទែនអ៊ុំ!

ខ៖ ហើយស្តាប់ទៅ, ស្តាំមុខហើយភ្លេចក្រោយទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយចេះតែចង់អោយគេនិយាយ!

ក៖ ចាសអ៊ុំ!

ខ៖ ដូចជាកូនរបស់ខ្ញុំគេចេះតែអានពីនេះពីនោះទៅ!

ក៖ ចាស!

ខ៖ ហើយចេះតែចង់ស្តាប់ទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ខ្ញុំចេះដែលតែចេះបន្តិតបន្តួតចេះប្រកប។

ក៖ ចាស! នឹងហើយអ៊ុំ!

ខ៖ ចាស! ចេះតែប្រកបទេ។

ក៖ អ៊ុំ! ឥឡូវនេះអ៊ុំដូចថាតើអ៊ុំមានបំណងចង់ចេះអានហើយចេះសរសេរដែលឬអត់? តើអ៊ុំគិតថាចង់រៀនដែលអត់? ដោយសារតែខ្ញុំគិតថាអ៊ុំនៅអាចរៀនបានចេះហើយសរសេរបានចឹងហាស់!

ខ៖ អ៊ុំ! ដូចជាអត់មាទេ ពិបាកម៉លអីមិនឃើញ។

ក៖ មើលអីអត់ឃើញហីអ៊ុំ?

ខ៖ ចាស! ពិបាកដោយសារតែភ្នែក។

ក៖ ភ្នែករបស់អ៊ុំវាស្រវាំងតើមែនទេ?

ខ៖ ចាពិបាកភ្នែកស្រវាំង។

ក៖ ចាស! ដូចម៉ាក់របស់ខ្ញុំដែលកុននឹងគាត់ចូលព្រះវិហារគាត់អត់ចេះសរសេរហើយក៏អត់ចេះអានដែល។

ខ៖ ចាស!

ក៖ តែនៅពេលដែលគាត់បានស្គាល់ដំណឹងល្អហាស់! ចូលជឿព្រះបិហារហាស់?

ខ៖ ចាស!

ក៖ ហើយអ្នកផ្សពផ្សាយសាសនាពួកគាត់មកបង្រៀន, ហើយអោយគាត់រៀនអានហាស់អ៊ុំ?

ខ៖ ចាស!

ក៖ ហើយកាលនឹងគាត់អត់ចេះអានទេ!

ខ៖ ចាស!

ក៖ តែឥឡូវនេះគាត់ចេះអានហើយគាត់ក៏ចេះសរសេរខ្លះៗដែល។

ខ៖ ចាស! តែខ្ញុំអត់ចេះទេ។

ក៖ ចាស!ប៉ុន្តែបើសិនជាអ៊ុំមានបំណងចង់រៀនហើយមានអ្នកគេមកបង្រៀបអ៊ុំមកដល់ផ្ទះតើអ៊ុំចង់រៀនដែលឬអត់?

ខ៖ រៀនឯណាបើអ៊ុំជាប់នៅមើលកីននៅនឹងផ្ទះនេះបាត់ហើយ។

ក៖ ចាស! អញ្ចឹងនឹងជាបញ្ហា។

ខ៖ ចាស!

ក៖ នឹង! អញ្ចឹងតើអ៊ុំមានអ្វីទៀតដែលអ៊ុំចង់ប្រាប់មកដល់ខ្ញុំដែលទេពីខ្សែជីវិតរបស់អ៊ុំកាលពីសម័យប៉ុលពតអីហើយពីសម័យឥឡូវនេះដែល?

ខ៖ ចាស! ខ្ញុំអស់ហើយ។

ក៖ អស់ហើយន៍អ៊ុំ?

ខ៖ ចាស! ជីវិតរបស់ខ្ញុំវាមានតែប៉ុននឹងឯង។

ក៖ ចាសអ៊ុំ! អញ្ចឹងខ្ញុំក៏អស់អីសួរទៅកាន់អ៊ុំដែលហើយ។

ខ៖ ចាស!

កៈ អញ្ចឹងខ្ញុំសូមអរគុណអ៊ំច្រើនមែនទែន។

ខៈ ចាអរគុណ!

កៈចាសអ៊ំ! ដែលបានអោយខ្ញុំធ្វើការសម្ភាសនៅថ្ងៃនេះ! អញ្ចឹងតើខ្ញុំសូមថតរូបអ៊ំស្រីមួយតើបានដែលទេ?

ខៈ ចាសថតចុះ។

កៈចាស! អរគុណច្រើនអ៊ំ៕